# ព្រះរាជក្រម

នស/រកម/០៦០៦/០១៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តុកខូម ស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានលទ្ធភាព ពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់នេះបានទាន់ពេលវេលាស្របតាមមាត្រា ១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាស្តុកខូមស្តីពីសារធាតុ បំពុលសរីរាង្គមិនងាយបំបែកធាតុ

**មាត្រា ១.—**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាស្តុកខូមស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដែលធ្វើនៅទីក្រុងស្តុកខូម ប្រទេសស៊ុយអែត នាថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.—**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៦

នស/រកម.០៦០៦.០២៧ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

លេខ: ៤៦០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

សេចក្តីបកប្រែមិនផ្លូវការ

# អនុសញ្ញា ស្តុកខូម ស្តីពី
# សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ

## ភាគីនៃអនុសញ្ញានេះ

- ទទួលស្គាល់ថា សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ គឺមានលក្ខណៈពុល (toxic) មិនងាយបំបែកធាតុ (persistant) និងមានភាពកំណើនបរិមាណក្នុងភាវៈរស់ ( មនុស្សឬសត្វ) (bioaccumulate) ហើយត្រូវបានសាយភាយតាមរយៈខ្យល់ ទឹក និងពពួកសត្វបំលាស់ទីឆ្លងកាត់ពីប្រទេសមួយទៅប្រទេសមួយ និងបានធ្លាក់កកផ្តុំឆ្ងាយពីប្រភពបញ្ចេញ ដែលនៅទីនោះពួកវាបានប្រមូលផ្តុំនៅក្នុងប្រព័ន្ធអេកូឡូស៊ីក្នុងទឹក និងលើគោក ។

- យល់ដឹងពីបញ្ហាសុខភាពសាធារណៈ ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាលទ្ធផលពីការទទួលរងនូវសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ជាពិសេសការប៉ះពាល់ទៅលើស្ត្រី ហើយតាមរយៈពួកគេនឹងបន្តទៅអ្នកជំនាន់ក្រោយ ។

- ទទួលស្គាល់ថាអេកូឡូស៊ីនៅតំបន់អាក់ទិក និងសហគមន៍ជនជាតិដែលរស់នៅទីនោះ គឺស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ ដោយសារតែភាពកំណើនបរិមាណពេលចំលងពីភាវៈរស់មួយទៅភាវៈរស់មួយ នៃសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ និងទទួលស្គាល់ថាការពុលនៃចំណីអាហាររបស់ពួកគេ គឺជាបញ្ហាសុខភាពសាធារណៈ។

- មានស្មារតីយល់ដឹងពីសេចក្តីត្រូវការ ដើម្បីជាវិធានការរួមលើបញ្ហាសារធាតុសរីរាង្គមិនងាយបំបែកធាតុ។

- យកចិត្តទុកដាក់លើសេចក្តីសំរេចលេខ ១៩ / ១៣គ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់ក្រុមប្រឹក្សាភិបាលអង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP Council) ដើម្បីផ្តួចផ្តើមជាវិធានការអន្តរជាតិសំរាប់ការពារសុខភាពមនុស្សនិងបរិស្ថាន តាមរយៈការកាត់បន្ថយឬលុបបំបាត់ចោលការសាយភាយ និងការបញ្ចេញចោលសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ។

- ចងចាំនូវបទបញ្ញត្តិផ្សេងៗ នៃអនុសញ្ញាបរិស្ថានអន្តរជាតិនានាដែលពាក់ព័ន្ធ ជាពិសេស អនុសញ្ញារ៉ូតើដាម (Rotterdam Convention) ស្តីពី គោលការណ៍កិច្ចព្រមព្រៀងជូនដំណឹងជាមុនសំរាប់សារធាតុគីមីប្រកបដោយគ្រោះថ្នាក់ និងថ្នាំពុលកសិកម្មមួយចំនួននៅក្នុងពាណិជ្ជកម្មពិភពលោក និងអនុសញ្ញាបាសែល (Basel) ស្តីពី ការត្រួតពិនិត្យចលនាឆ្លងដែននៃសំណល់ប្រកបដោយគ្រោះថ្នាក់និងការបោះបង់ចោល ដោយរាប់បញ្ចូលទាំងកិច្ចព្រមព្រៀងថ្នាក់តំបន់ដែលបានបង្កើតឡើងនៅក្នុងក្របខ័ណ្ឌនៃមាត្រា ១១ នៃអនុសញ្ញានេះ ។

- ចងចាំផងដែរនូវបទបញ្ញត្តិផ្សេងៗ នៃសេចក្តីប្រកាសនៅទីក្រុងរីយ៉ូ (Rio) ស្តីពីការអភិវឌ្ឍន៍និងបរិស្ថាន ព្រមទាំងរបៀបវារៈ ២១ (Agenda 21) ។

- ទទួលស្គាល់ថា ការប្រុងប្រយ័ត្នជាមុនជាចំនុចយកចិត្តទុកដាក់របស់ភាគីទាំងអស់ ដែលនឹងចែងក្នុងអនុសញ្ញានេះ។

- ទទួលស្គាល់ថា អនុសញ្ញានេះនិងកិច្ចព្រមព្រៀងអន្តរជាតិនានានៅក្នុងវិស័យពាណិជ្ជកម្មនិងបរិស្ថាន គឺមានការគាំទ្រគ្នាទៅវិញទៅមក ។

- អះអាងជាថ្មីថា ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងគោលការណ៍ច្បាប់អន្តរជាតិ រដ្ឋទាំងអស់មានសិទ្ធិអធិបតេយ្យភាព ដើម្បីធ្វើអាជីវកម្មលើធនធាននានារបស់ពួកគេ ដែលស្របទៅតាមគោលនយោបាយនៃការអភិវឌ្ឍន៍ និងបរិស្ថានរបស់ពួកគេផ្ទាល់ ហើយរដ្ឋទាំងនោះត្រូវមានភាពទទួលខុសត្រូវរៀងៗខ្លួនដើម្បីធានាថា រាល់សកម្មភាពនៅក្នុងយុត្តាធិការរបស់ពួកគេ គឺមិនបង្កឱ្យមានមហន្តរាយបរិស្ថានរបស់រដ្ឋដទៃ ឬដល់តំបន់ដទៃដែលហួសពីការកំណត់នៃយុត្តាធិការរបស់ពួកគេ ។

- យកចិត្តទុកដាក់ពីកាលៈទេសៈ និងតំរូវការចាំបាច់នានារបស់ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច និងប្រទេសដែលសេដ្ឋកិច្ចស្ថិតក្នុងអន្តរកាល លើការយកចិត្តទុកដាក់ពីតំរូវការដើម្បីជួយពង្រឹងសមត្ថភាពជាតិរបស់ពួកគេសំរាប់ការគ្រប់គ្រងសារធាតុគីមី តាមរយៈការផ្ទេរនូវបច្ចេកវិទ្យា ការផ្តល់ជំនួយថវិកា និងបច្ចេកទេស ព្រមទាំងការបង្កើននូវកិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីជាសមាជិក ។

- យកចិត្តទុកដាក់ពីកម្មវិធីជាសកម្មភាពសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព នៃរដ្ឋកំពុងអភិវឌ្ឍន៍នៅតាមកោះតូចៗ ដូចដែលបានអនុម័តនៅបាបាដូស (Barbados) នាថ្ងៃទី ៦ ខែឧសភា ឆ្នាំ១៩៩៤ ។

- កំណត់ពីសមត្ថភាពដោយឡែកនៃប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ ក៏ដូចជាសមត្ថភាពរួម ប៉ុន្តែការទទួលខុសត្រូវផ្សេងៗគ្នារបស់រដ្ឋនិមួយៗ ដូចដែលបានចែងនៅក្នុងគោលការណ៍ទី ៧ នៃសេចក្តីប្រកាសក្រុងរីយ៉ូ ស្តីពីការអភិវឌ្ឍន៍និងបរិស្ថាន។

- ទទួលស្គាល់នូវសារៈសំខាន់នៃការចូលរួមវិភាគទានពីស្ថាប័នឯកជននិងអង្គការក្រៅរដ្ឋាភិបាល ដែលអាចធ្វើឱ្យសំរេចបានការកាត់បន្ថយ ឬការលុបបំបាត់ការសាយភាយ និងការបញ្ចេញចោលសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ។

- គូសបញ្ជាក់ពីភាពសំខាន់នៃអ្នកផលិតសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ក្នុងការទទួលខុសត្រូវកាត់បន្ថយហេតុប៉ះពាល់អាក្រក់ដែលបង្កដោយផលិតផលរបស់ពួកគេ និងក្នុងការទទួលខុសត្រូវផ្តល់ពត៌មាននានាដល់អ្នកប្រើប្រាស់ រដ្ឋាភិបាល និងសាធារណៈជនអំពីភាពប្រកបដោយគ្រោះថ្នាក់របស់សារធាតុគីមីទាំងនោះ ។

- មានស្មារតីយល់ដឹងពីសេចក្តីតំរូវ ដើម្បីចាត់វិធានការការពារឥទ្ធិពលអាក្រក់បង្កឡើងដោយសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុនៅរាល់ដំណាក់កាលនៃវដ្តរបស់វា ។

- អះអាងបញ្ជាក់ជាថ្មីថា នូវគោលការណ៍ទី ១៦ នៃសេចក្តីប្រកាសនៅទីក្រុងរីយ៉ូ ស្តីពី ការអភិវឌ្ឍន៍និងបរិស្ថាន ដែលចែងថា អាជ្ញាធរជាតិត្រូវខិតខំដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពរួមនៃតំលៃបរិស្ថាន និងការប្រើប្រាស់បរិធានសេដ្ឋកិច្ច ដោយយកចិត្តទុកដាក់លើដំណោះស្រាយគោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតំលៃនៃការបំពុល ដែលទាក់ទងទៅនឹងផលប្រយោជន៍សាធារណៈ និងមិនធ្វើឱ្យមានការរំខានដល់ការធ្វើវិនិយោគទុននិងការធ្វើជំនួញអន្តរជាតិ ។

- ខិតខំជំរុញភាគីដែលមិនទាន់មានប្រព័ន្ធវាយតំលៃ និងបទបញ្ញត្តិសំរាប់សារធាតុគីមីឧស្សាហកម្ម និងថ្នាំសំលាប់សត្វល្អិត ដើម្បីរៀបចំនូវប្រព័ន្ធទាំងនោះ ។

- ទទួលស្គាល់នូវភាពសំខាន់នៃការបង្កើតនិងការប្រើប្រាស់ជំរើសថ្មីនៃសារធាតុគីមី ដំណើរការផលិតកម្មដែលធ្វើឱ្យមានសុវត្ថិភាពបរិស្ថាន ។

- កំណត់កិច្ចការពារសុខភាពសាធារណៈ និងកិច្ចការពារបរិស្ថានឱ្យចៀសផុតពីផលប៉ះពាល់ជាគ្រោះថ្នាក់ដែលបង្កឡើងដោយសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ។

**បានយល់ព្រមដូចតទៅ :**

**មាត្រា ១ : កម្មវត្ថុ**

ដោយផ្តោតការយកចិត្តទុកដាក់នូវដំណោះស្រាយក្នុងភាពប្រុងប្រយ័ត្នទុកជាមុន ដូចដែលមានចែងនៅក្នុងគោលការណ៍ទី ១៥ នៃសេចក្តីប្រកាសទៅទីក្រុងរីយ៉ូ ស្តីពីការអភិវឌ្ឍន៍និងបរិស្ថាន អនុសញ្ញានេះមានគោលបំណង ដើម្បីការពារសុខភាពសាធារណៈនិងបរិស្ថាន ឱ្យចៀសផុតពីឥទ្ធិពលគ្រោះថ្នាក់នៃសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ។

**មាត្រា ២ : និយមន័យ**

សំរាប់គោលបំណងនៃអនុសញ្ញានេះ :

ក- ***ភាគីជាសមាជិក*** គឺសំដៅលើរដ្ឋ ឬអង្គការសេដ្ឋកិច្ចរួមតំបន់ ដែលបានយល់ព្រមទទួលអនុវត្តនូវអនុសញ្ញានេះ នៅពេលដែលអនុសញ្ញានេះកំពុងទៅជាធរមាន ។

ខ- ***អង្គការសេដ្ឋកិច្ចរួមតំបន់*** គឺសំដៅលើអង្គការ ដែលត្រូវបានបង្កើតដោយរដ្ឋអធិបតេយ្យភាពក្នុងតំបន់ ហើយរដ្ឋជាសមាជិកនៃអង្គការនោះបានផ្ទេរសមត្ថកិច្ច និងសិទ្ធិអំណាចទៅឱ្យអង្គការនោះ និងត្រូវបានទទួលសិទ្ធយ៉ាងពេញលេញដើម្បីចុះហត្ថលេខា ផ្តល់សច្ចានុម័ត ទទួលយកយល់ព្រមឬសុំចូលជាសមាជិកអនុសញ្ញានេះដោយអនុលោមទៅតាមគោលការណ៍ផ្ទៃក្នុងរបស់អង្គការនោះ ។

គ- ***ការបោះឆ្នោតនិងវត្តមានរបស់ភាគី*** គឺសំដៅលើវត្តមានរបស់ភាគីជាសមាជិក និងការបោះឆ្នោតរបស់ភាគីជាវិជ្ជមាន ឬអវិជ្ជមាន ។

**មាត្រា ៣ : វិធានការកាត់បន្ថយឬលុបបំបាត់ការភាយចេញពីការផលិតនិងការប្រើប្រាស់ដោយចេតនា**

១- ភាគីនិមួយៗត្រូវ :

ក- ហាមឃាត់ និងចាត់វិធានការចាំបាច់តាមផ្លូវច្បាប់ និងរដ្ឋបាលដើម្បីលុបបំបាត់ :

(i) ការផលិត និងការប្រើប្រាស់របស់គេនូវសារធាតុគីមីដែលមានចែងនៅក្នុងឧបសម្ព័ន្ធ (ក) ដោយអនុលោមទៅតាមបទបញ្ញត្តិនៃឧបសម្ព័ន្ធនោះ ។

(ii) ការនាំចូល និងការនាំចេញរបស់គេនូវសារធាតុគីមី ដែលមានចែងនៅក្នុងឧបសម្ពន្ធ (ក) ដោយអនុលោមទៅតាមបទបញ្ញត្តិនៃវាក្យខ័ណ្ឌ ២ ។

ខ- ដាក់កំរិតលើការផលិត និងការប្រើប្រាស់របស់គេនូវសារធាតុគីមី ដែលមានចែងនៅក្នុងឧបសម្ពន្ធ (ខ) ដោយអនុលោមទៅតាមបទបញ្ញត្តិនៃឧបសម្ពន្ធនោះ ។

២ - ភាគីនិមួយៗត្រូវចាត់វិធានការនានាដើម្បីធានាថា :

ក- សារធាតុគីមីដែលមានចែងនៅក្នុងឧបសម្ពន្ធ (ក) ឬឧបសម្ពន្ធ (ខ) ត្រូវបានគេនាំចូលត្រឹមតែ :

(i) សំរាប់គោលបំណងនៃការបោះបង់ចោលប្រកបដោយសុវត្ថិភាពបរិស្ថាន ដូចដែលមានចែងនៅក្នុងវាក្យខ័ណ្ឌ ១ (ឃ) នៃមាត្រា ៦ ឬ

(ii) សំរាប់ការប្រើប្រាស់ ឬក្នុងគោលបំណង ដែលត្រូវបានផ្តល់ការអនុញ្ញាតឱ្យភាគីនោះនៅក្រោមឧបសម្ពន្ធ (ក) ឬ ឧបសម្ពន្ធ (ខ) ។

ខ- សារធាតុគីមីចែងនៅក្នុងឧបសម្ពន្ធ (ក) ដែលករណីលើកលែងពិសេសនៃការផលិត ឬការប្រើប្រាស់នៃសារធាតុគីមីនៅមានប្រសិទ្ធិភាព ឬសារធាតុគីមីចែងនៅក្នុងឧបសម្ពន្ធ (ខ) ដែលករណីលើកលែងពិសេស ឬគោលបំណងដែលអាចទទួលយកបាននៃការផលិតឬប្រើប្រាស់នៅមានប្រសិទ្ធិភាព ដោយធ្វើការយកចិត្តទុកដាក់ពីបទបញ្ញត្តិពាក់ព័ន្ធនានា ដែលមាននៅក្នុងបរិធានអន្តរជាតិស្តីពីការព្រមព្រៀងជូនដំណឹងជាមុន (PIC) ត្រូវបាននាំចេញ :

(i) សំរាប់គោលបំណងនៃការបោះបង់ចោលប្រកបទៅដោយសុវត្ថិភាពបរិស្ថាន ដូចដែលមានចែងនៅក្នុងវាក្យខ័ណ្ឌ ១ (ឃ) នៃមាត្រា ៦ ។

(ii) ទៅកាន់ភាគីដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់នូវសារធាតុគីមីចែងក្នុងឧបសម្ពន្ធ (ក) ឬ ឧបសម្ពន្ធ (ខ) ។

(iii) ទៅកាន់ប្រទេសមិនមែនជាភាគីនៃអនុសញ្ញានេះ ដែលបានផ្តល់នូវវិញ្ញាបនប័ត្រប្រចាំឆ្នាំទៅភាគីធ្វើការនាំចេញ ។ វិញ្ញាបនប័ត្រនោះត្រូវបញ្ជាក់ឱ្យបានច្បាស់នូវគោលបំណងនៃការប្រើប្រាស់នូវសារធាតុគីមីនោះ និងមានបញ្ចូលនូវសេចក្តីរាយការណ៍ថា ទាក់ទងនឹងសារធាតុគីមីនាំចូលនោះ ប្រទេសជាអ្នកនាំចូលសារធាតុគីមីនោះបានសន្យា :

- ការពារសុខភាពសាធារណៈនិងបរិស្ថាន ដោយចាត់វិធានការចាំបាច់នានាដើម្បីកាត់បន្ថយ ឬទប់ស្កាត់ការសាយភាយ ។
- អនុវត្តន៍តាមបទបញ្ញត្តិនានានៃវាក្យខ័ណ្ឌ ១ ក្នុងមាត្រា ៦។ និង
- អនុវត្តន៍តាមបទបញ្ញត្តិនានានៃវាក្យខ័ណ្ឌ ២ ផ្នែកទី ២ នៃឧបសម្ពន្ធ (ខ) ។

វិញ្ញាបនប័ត្រនោះ ត្រូវបញ្ចូលនូវឯកសារយោងសមស្របមួយចំនួន ដូចជា ច្បាប់ បរិធានគតិតតំណត់ ឬគោលការណ៍ណែនាំរដ្ឋបាល និងគោលនយោបាយនានា ។ ភាគីអ្នកនាំចេញត្រូវបញ្ជូនវិញ្ញាបនប័ត្រនោះទៅកាន់លេខាធិការដ្ឋានអនុសញ្ញាក្នុងរយៈ ៦០ ថ្ងៃនៃការទទួល ។

គ- សារធាតុគីមីដែលចែងនៅក្នុងឧបសម្ព័ន្ធ ( ក ) ដែលករណីលើកលែងពិសេសនៃការផលិត និងការប្រើប្រាស់នៃសារធាតុគីមីទាំងនោះនៅមានប្រសិទ្ធិភាពក្នុងរយៈពេលខ្លី សំរាប់ភាគីជាសមាជិកណាក៏ដោយនឹងមិនអនុញ្ញាតឱ្យនាំចេញពីប្រទេសខ្លួន លើកលែងតែការនាំចេញនោះសំរាប់គោលបំណងនៃការបោះបង់ចោលប្រកបដោយសុវត្ថិភាពបរិស្ថាន ដូចដែលមានចែងក្នុងវាក្យខ័ណ្ឌ ១ ( ឃ ) មាត្រា ៦ ។

ឃ- សំរាប់គោលបំណងនៃវាក្យខ័ណ្ឌនេះ "**ប្រទេសមិនមែនជាសមាជិកនៃអនុសញ្ញានេះ**" គឺសំដៅលើរដ្ឋ ឬអង្គការសេដ្ឋកិច្ចរួមតំបន់ដែលមិនបានយល់ព្រមចុះហត្ថលេខាលើអនុសញ្ញានេះ ចំពោះសារធាតុគីមីទាំងនោះ ។

៣- ភាគីនិមួយៗ ដែលមានប្រព័ន្ធវាយតំលៃនិងបទបញ្ញាមួយ ឬច្រើនសំរាប់ថ្នាំសំលាប់សត្វល្អិតប្រភេទថ្មី ឬសារធាតុគីមីឧស្សាហកម្មប្រភេទថ្មី ត្រូវចាត់វិធានការដាក់កំរិតក្នុងគោលបំណងទប់ស្កាត់ការផលិត និងការប្រើប្រាស់នូវថ្នាំសំលាប់សត្វល្អិតប្រភេទថ្មី ឬសារធាតុគីមីឧស្សាហកម្មប្រភេទថ្មី ដែលបានបង្ហាញនូវលក្ខណៈជាសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដោយធ្វើការពិចារណាទៅលើល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងវាក្យខ័ណ្ឌ ១ នៃឧបសម្ព័ន្ធ ( ឃ ) ។

៤- ភាគីនិមួយៗ ដែលមានប្រព័ន្ធវាយតំលៃនិងប្រព័ន្ធច្បាប់មួយ ឬច្រើនសំរាប់ថ្នាំសំលាប់សត្វល្អិត ឬសារធាតុគីមីឧស្សាហកម្ម ត្រូវធ្វើការពិចារណាក្នុងប្រព័ន្ធនោះនូវល័ក្ខខ័ណ្ឌដូចបានចែងនៅក្នុងវាក្យខ័ណ្ឌ ១ នៃឧបសម្ព័ន្ធ ( ឃ ) នៅពេលធ្វើការវាយតំលៃពីថ្នាំសំលាប់សត្វល្អិត ឬសារធាតុគីមីឧស្សាហកម្មដែលកំពុងប្រើប្រាស់ ។

៥- លើកលែងនូវអ្វីដែលបានចែងក្នុងអនុសញ្ញានេះ វាក្យខ័ណ្ឌ ១ និង វាក្យខ័ណ្ឌ ២ នឹងមិនអនុវត្តន៍ចំពោះបរិមាណសារធាតុគីមី ដែលត្រូវប្រើប្រាស់សំរាប់ការស្រាវជ្រាវនៅក្នុងមន្ទីរពិសោធន៍ ឬសំរាប់ជាបទដ្ឋានយោងនានាឡើយ ។

៦- ភាគីណាមួយ ដែលមានករណីលើកលែងពិសេសដោយអនុលោមតាមឧបសម្ព័ន្ធ ( ក ) ឬករណីលើកលែងពិសេស ឬគោលបំណងដែលអាចទទួលយកបាន ដោយអនុលោមតាមឧបសម្ព័ន្ធ ( ខ ) ត្រូវចាត់វិធានការសមស្របដើម្បីធានាថាការផលិត ឬការប្រើប្រាស់សារធាតុគីមី ដែលស្ថិតនៅក្រោមករណីលើកលែង ឬគោលបំណងបែបនេះ ត្រូវបានអនុវត្តន៍តាមវិធីមួយដែលទប់ស្កាត់ ឬកាត់បន្ថយឥទ្ធិពលទទួលរងទៅលើមនុស្ស និងការសាយភាយចូលទៅក្នុងបរិស្ថាន ។ សំរាប់ការប្រើប្រាស់ដែលស្ថិតនៅក្នុងករណីលើកលែងពិសេស ឬគោលបំណងដែលអាចទទួលយកបានដែលពាក់ព័ន្ធនឹងការភាយចេញដោយចេតនាទៅក្នុងបរិស្ថាន នៅក្រោម

ល័ក្ខខ័ណ្ឌការប្រើប្រាស់ធម្មតា ការភាយចេញនេះត្រូវតែកំណត់ឱ្យមានកំរិតអប្បបរមាជាការចាំបាច់ ដោយយកចិត្តទុកដាក់ទៅលើបទដ្ឋាន និងគោលការណ៍ណែនាំដែលមាន ។

**មាត្រា ៤ : បញ្ជីសំរាប់ករណីលើកលែងពិសេស**

១- បញ្ជីនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងធ្វើការកំណត់នូវភាគីជាសមាជិក ដែលទទួលបានករណីលើកលែងពិសេស ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ (ក) ឬ ឧបសម្ព័ន្ធ (ខ) ។ បញ្ជីនេះនឹងមិនកំណត់នូវភាគីជាសមាជិកដែលធ្វើការប្រើប្រាស់នូវបទបញ្ញត្តិនៅក្នុងឧបសម្ព័ន្ធ (ក) ឬ ឧបសម្ព័ន្ធ (ខ) ដែលអាចត្រូវបានអនុវត្តន៍ដោយរាល់ភាគីជាសមាជិក ។ បញ្ជីនេះនឹងត្រូវបានរក្សាទុកដោយលេខាធិការដ្ឋាន និងត្រូវផ្តល់ជាសាធារណៈតាមតំរូវការ ។

២- បញ្ជីនេះត្រូវរួមបញ្ចូល :

ក- តារាងប្រភេទនៃការលើកលែងពិសេស ដែលកើតចេញពីតារាងឧបសម្ព័ន្ធ(ក) និងឧបសម្ព័ន្ធ(ខ) ។

ខ- តារាងភាគីសមាជិកដែលទទួលបានការលើកលែងពិសេស ដែលមានចែងក្រោមឧបសម្ព័ន្ធ (ក) ឬ ឧបសម្ព័ន្ធ (ខ) ។

គ- តារាងកាលបរិច្ឆេទហួសកំណត់ សំរាប់ករណីលើកលែងពិសេសនិមួយៗដែលបានចុះបញ្ជីគន្លងមក ។

៣- នៅពេលក្លាយជាភាគីអនុសញ្ញានេះ ដោយតាមរយៈការជូនដំណឹងលាយល័ក្ខអក្សរទៅលេខាធិការដ្ឋាន រដ្ឋជាភាគីអាចធ្វើការចុះបញ្ជីមួយ ឬច្រើននៃប្រភេទករណីលើកលែងពិសេសដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ក ឬ ឧបសម្ព័ន្ធ ខ ។

៤- ដោយមិនគិតពីកាលបរិច្ឆេទមុនដំបូងដែលបានចុះនៅក្នុងបញ្ជីដោយភាគីមួយ ឬការពន្យារពេលត្រូវបានផ្តល់ឱ្យដោយអនុលោមទៅតាមវាក្យខ័ណ្ឌ ៧ រាល់ការចុះបញ្ជីករណីលើកលែងពិសេស នឹងត្រូវផុតកំណត់ក្នុងរយៈពេល ៥ ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ សំរាប់សារធាតុគីមីនិមួយៗ ។

៥- នៅក្នុងកិច្ចប្រជុំលើកទី ១ សន្និបាតភាគីត្រូវធ្វើការសំរេចលើការសុំចុះបញ្ជី ដោយផ្អែកលើដំណើរការពិនិត្យឡើងវិញរបស់ខ្លួន។

៦- មុនការពិនិត្យឡើងវិញនៃការសុំចុះបញ្ជីនោះ ភាគីជាសមាជិកពាក់ព័ន្ធត្រូវដាក់ស្នើនូវរបាយការណ៍ទៅលេខាធិការដ្ឋាន ដើម្បីធ្វើការកែសំរួលតំរូវការជាបន្តរបស់ភាគីជាសមាជិកសំរាប់ការចុះបញ្ជីករណីលើកលែងពិសេសនោះ ។ របាយការណ៍នឹងត្រូវបានបញ្ជូនទៅគ្រប់ភាគីទាំងអស់ដោយលេខាធិការដ្ឋានទៅកាន់ ។ ការពិនិត្យឡើងវិញនូវការចុះបញ្ជី នឹងត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃរាល់ពត៌មានដែលអាចមាន ហើយសន្និបាតភាគីអាចផ្តល់ជាអនុសាសន៍ទៅសមាជិកពាក់ព័ន្ធ ក្នុងករណីដែលយល់ឃើញថាវាសមស្រប ។

**៧-** យោងទៅលើសំណូមពរពីសមាជិកពាក់ព័ន្ធ សន្និបាតភាគីអាចសំរេចបន្តនូវកាលបរិច្ឆេទនៃករណីលើកលែងពិសេសក្នុងរយៈពេល ៥ ឆ្នាំថែមទៀត ។ នៅក្នុងការធ្វើសេចក្តីសំរេចរបស់ខ្លួន សន្និបាតភាគីត្រូវគិតគូរអំពីកាលៈទេសៈពិសេសនៃសមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងជាប្រទេសសេដ្ឋកិច្ចអន្តរកាល ។

**៨-** ក្នុងពេលណាមួយ ភាគីជាសមាជិកអាចដកខ្លួនចេញពីបញ្ជីសំរាប់ករណីលើកលែងពិសេស តាមរយៈការជូនដំណឹងជាលាយល័ក្ខអក្សរទៅកាន់លេខាធិការដ្ឋាន ។ ការដកខ្លួនចេញត្រូវចូលជាធរមាននៅថ្ងៃដែលមានកំណត់នៅក្នុងលិខិតជូនដំណឹង ។

**៩-** នៅពេលដែលគ្មានភាគីសុំធ្វើការចុះបញ្ជីសំរាប់ករណីលើកលែងពិសេស នោះការចុះបញ្ជីនឹងត្រូវបញ្ចប់ ។

## <u>មាត្រា ៥</u> : វិធានការកាត់បន្ថយ ឬលុបបំបាត់ការសាយភាយចេញពីការផលិតដោយអចេតនា

ភាគីនិមួយៗ យ៉ាងហោចណាស់ត្រូវចាត់វិធានការដូចខាងក្រោម ដើម្បីកាត់បន្ថយរាល់ការសាយភាយដែលកើតមកពីប្រភពសកម្មភាពរបស់មនុស្សនូវសារធាតុគីមីនិមួយៗ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ (គ) ដោយក្នុងគោលបំណង ធ្វើឱ្យថយចុះជាបន្តបន្ទាប់ និងតាមដែលអាចឈានទៅលុបបំបាត់ចោលទាំងស្រុង :

**ក-** ត្រូវរៀបចំផែនការសកម្មភាព ឬផែនការសកម្មភាពតំបន់ ឬអនុតំបន់តាមដែលអាច សំរាប់រយៈពេល ២ ឆ្នាំ គិតចាប់តាំងពីថ្ងៃចូលជាភាគីសមាជិកអនុសញ្ញានេះ និងអនុវត្តន៍ជាបន្តបន្ទាប់នូវផែនការនោះ ដែលវាជាផ្នែកមួយនៃផែនការអនុវត្តអនុសញ្ញាដូចមានចែងនៅក្នុងមាត្រា ៧ ដែលបានគ្រោងដើម្បីកំណត់នូវលក្ខណៈ និងបរិមាណសាយភាយនៃសារធាតុគីមីដែលមានចែងនៅក្នុងឧបសម្ព័ន្ធ (គ) និងដើម្បីសំរបសំរួលការអនុវត្តន៍ចំណុចក្នុងកថាខ័ណ្ឌ (ខ) ទៅដល់ (ង) ។ ផែនការសកម្មភាពត្រូវរាប់បញ្ចូលនូវចំណុចមួយចំនួន ដូចខាងក្រោម :

(i) ការវាយតំលៃពីការសាយភាយពេលបច្ចុប្បន្ន និងការសាយភាយដែលបានគ្រោងដោយរួមបញ្ចូលទាំងការធ្វើសារពើភ័ណ្ឌប្រភព និងការប៉ាន់ប្រមាណលើការសាយភាយដោយយកចិត្តទុកដាក់ពីប្រភេទនៃប្រភពដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធ (គ) ។

(ii) ការវាយតំលៃពីប្រសិទ្ធិភាពនៃច្បាប់ និងគោលនយោបាយរបស់ភាគីជាសមាជិកដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងនៃការសាយភាយនោះ ។

(iii) ផែនការយុទ្ធសាស្ត្រដើម្បីឆ្លើយតបទៅនឹងកាតព្វកិច្ច ដែលចែងនៅក្នុងវាក្យខ័ណ្ឌនេះ ដោយយកចិត្តទុកដាក់ពីការវាយតំលៃដែលបានចែងនៅក្នុងចំនុច (i) និងចំនុច (ii) ។

(iv) វិធានការដើម្បីបង្កើនការអប់រំ និងការបណ្តុះបណ្តាលឱ្យយល់ដឹងពីផែនការយុទ្ធសាស្ត្រទាំងនោះ ។

(v) ការពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្ររៀងរាល់ ៥ ឆ្នាំម្តង និងពីលទ្ធផលសំរេចបាននៃផែនការយុទ្ធសាស្ត្រក្នុងការឆ្លើយតបទៅនឹងកាតព្វកិច្ច ដែលមានចែងនៅក្នុង

វាក្យខ័ណ្ឌនេះ។ ការពិនិត្យឡើងវិញនេះនឹងត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ដែលត្រូវដាក់ជូនទៅលេខាធិការដ្ឋានអនុលោមទៅតាមមាត្រា ១៥ ។

(vi) កម្មវិធីសំរាប់អនុវត្តន៍ផែនការសកម្មភាព ដោយរួមបញ្ចូលទាំងកម្មវិធីសំរាប់យុទ្ធសាស្ត្រ និងវិធានការនានាដូចដែលបានបញ្ជាក់នៅខាងលើស្រាប់ ។

ខ- ត្រូវបង្កើនការអនុវត្តន៍នូវវិធានការដែលសមស្រប ដែលងាយរកបាននិងអាចធ្វើបាន ហើយដែលអាចសំរេចបានយ៉ាងប្រាកដ និងកំរិតខ្ពស់នៃការកាត់បន្ថយការសាយភាយ ឬការលុបបំបាត់ចោលនូវប្រភព ។

គ- ត្រូវបង្កើនការអភិវឌ្ឍន៍ និងការតំរូវលើការប្រើប្រាស់ជំនួស ឬការប្រើប្រាស់ដំណើរការផលិតកម្មផលិតផល និងសំភារៈដែលបានធ្វើការកែប្រែ នៅពេលយល់ថាជាការសមស្រប ដើម្បីទប់ស្កាត់ការបង្កើត និងការសាយភាយនូវសារធាតុគីមី ដែលមានចែងក្នុងឧបសម្ព័ន្ធ (គ) ដោយគិតពិចារណាអំពីការណែនាំទូទៅលើការការពារ និងវិធានការកាត់បន្ថយការសាយភាយសារធាតុគីមីនៅក្នុងឧបសម្ព័ន្ធ (គ) និងការណែនាំដែលនឹងត្រូវបានអនុម័តដោយការសំរេចរបស់សន្និបាតភាគី ។

ឃ- ដោយអនុលោមទៅតាមកម្មវិធីអនុវត្តន៍នៃផែនការសកម្មភាពរបស់ពួកគេ ត្រូវបង្កើន និងតំរូវឱ្យប្រើប្រាស់នូវបច្ចេកទេសដ៏ប្រសើរដែលអាចរកបាន (Best Available Techniques, BAT) សំរាប់ប្រភពថ្មី ក្នុងចំណាត់ថ្នាក់ប្រភពដែលភាគីជាសមាជិកបានកំណត់ជាវិធានការនៅក្នុងផែនការសកម្មភាពរបស់គេ ដោយផ្តោតជាបឋមទៅលើចំណាត់ថ្នាក់ប្រភពដែលបានកំណត់នៅក្នុងផ្នែកទី ២ នៃឧបសម្ព័ន្ធ (គ) ។ នៅក្នុងករណីមួយចំនួន ការតំរូវឱ្យប្រើប្រាស់បច្ចេកទេសដ៏ប្រសើរដែលអាចរកបានសំរាប់ប្រភពថ្មី នៅក្នុងចំណាត់ថ្នាក់ដែលមានចែងនៅក្នុងផ្នែកទី ២ នៃឧបសម្ព័ន្ធ (គ) ត្រូវបានដាក់បញ្ចូលឱ្យអនុវត្តន៍ឱ្យបានឆាប់តាមដែលអាចធ្វើបាន ប៉ុន្តែមិនឱ្យយឺតជាង ៤ ឆ្នាំ បន្ទាប់ពីការចូលជាភាគីសមាជិកនៃអនុសញ្ញានេះ។ សំរាប់ប្រភេទដែលបានចំណាត់ថ្នាក់ ភាគីជាសមាជិកត្រូវបង្កើនការប្រើប្រាស់កិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ (Best Environmental Practices, BEP) ។ នៅពេលអនុវត្តនូវបច្ចេកទេសដ៏ប្រសើរដែលអាចរកបាន និងកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ ភាគីជាសមាជិកទាំងអស់ត្រូវយកចិត្តទុកដាក់លើការណែនាំទូទៅពីការទប់ស្កាត់ និងវិធានការកាត់បន្ថយការសាយភាយនៅក្នុងឧបសម្ព័ន្ធ (គ) និងគោលការណ៍ណែនាំ ស្តីពី បច្ចេកទេសដ៏ប្រសើរដែលអាចរកបាន និងកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរដែលនឹងត្រូវបានអនុម័តដោយការសំរេចរបស់សន្និបាតភាគី។

ង- ដោយអនុលោមទៅតាមផែនការសកម្មភាពរបស់គេ ត្រូវបង្កើនការប្រើប្រាស់បច្ចេកទេសដ៏ប្រសើរដែលអាចរកបាន និងកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ :

(i) សំរាប់ប្រភពដែលមានស្រាប់ នៅក្នុងចំណាត់ថ្នាក់ប្រភពដែលមានចែងក្នុងផ្នែកទី ២ នៃឧបសម្ព័ន្ធ (គ) និងនៅក្នុងចំណាត់ថ្នាក់ប្រភពដែលមានចែងក្នុងផ្នែកទី ៣ នៃឧបសម្ព័ន្ធ (គ) ។

(ii) សំរាប់ប្រភពថ្មី នៅក្នុងចំណាត់ថ្នាក់ប្រភពដែលមានចែងនៅក្នុងផ្នែកទី ៣ នៃឧបសម្ព័ន្ធ (គ) ដែលភាគីជាសមាជិកមិនបានដោះស្រាយនៅក្នុងវាក្យខ័ណ្ឌ (ឃ)ខាងលើ ។

នៅពេលធ្វើការអនុវត្តន៍នូវបច្ចេកទេសដ៏ប្រសើរដែលអាចរកបាន និងកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ ភាគីសមាជិក ត្រូវយកចិត្តទុកដាក់លើការណែនាំទូទៅលើការការពារ និងវិធានការកាត់បន្ថយការសាយភាយ នៅក្នុងឧបសម្ព័ន្ធ (គ) និងគោលការណ៍ណែនាំ ស្តីពី បច្ចេកទេសដ៏ប្រសើរដែលអាចរកបាន និងកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ ដែលនឹងត្រូវបានអនុម័តដោយការសំរេចរបស់សន្និបាតភាគីសមាជិក ។

ច- សំរាប់គោលបំណងនៃវាក្យខ័ណ្ឌនេះ និងឧបសម្ព័ន្ធ (គ) :

(i) **បច្ចេកទេសដ៏ប្រសើរដែលអាចរកបាន** : គឺសំដៅលើវិធានការដែលមានសារៈប្រយោជន៍ខ្ពស់ និងមានប្រសិទ្ធិភាពបំផុត ក្នុងការរៀបចំសកម្មភាព និងវិធីសាស្ត្រប្រតិបត្តិរបស់ពួកគេ ដែលបង្ហាញនូវភាពសមស្របនៃការប្រតិបត្តិបច្ចេកទេសពិសេស សំរាប់ផ្តល់ជាគោលការណ៍មូលដ្ឋាន សំរាប់កាត់បន្ថយការបញ្ចេញ ( សំរាប់កន្លែងដែលមិនធ្លាប់បានអនុវត្តន៍ ) ដែលបានគ្រោង ដើម្បីទប់ស្កាត់ និងកាត់បន្ថយការសាយភាយនូវសារធាតុគីមីដែលមានចែងនៅក្នុងផ្នែកទី ១ នៃឧបសម្ព័ន្ធ (គ) និងកាត់បន្ថយហេតុប៉ះពាល់របស់វាទៅលើបរិស្ថានទាំងមូល ។

(ii) **បច្ចេកទេស** : គឺសំដៅទាំងទៅលើបច្ចេកវិទ្យាដែលបានប្រើ និងវិធីដែលនៅក្នុងនោះការតំឡើង បំពាក់ ត្រូវបានគ្រោង សាងសង់ ថែរក្សា ប្រតិបត្តិ និងបញ្ឈប់ ។

(iii) **បច្ចេកទេសដែលអាចរកបាន** : គឺសំដៅលើរាល់បច្ចេកទេស ដែលអាចផ្តល់លទ្ធភាពដល់អ្នកប្រតិបត្តិ និងដែលត្រូវបានគេបង្កើតឡើងនៅក្នុងកំរិតមួយដែលអនុញ្ញាតឱ្យអនុវត្តន៍នៅក្នុងផ្នែកឧស្សាហកម្មដែលពាក់ព័ន្ធ និងស្ថិតនៅក្រោមល័ក្ខខ័ណ្ឌសេដ្ឋកិច្ច និងបច្ចេកវិទ្យាដោយយកចិត្តទុកដាក់ពីតំលៃ និងអត្ថប្រយោជន៍ផងដែរ ។

(iv) **ដ៏ប្រសើរ** : គឺសំដៅលើប្រសិទ្ធិភាពខ្ពស់ក្នុងការសំរេចឱ្យបាននូវកំរិតទូទៅដ៏ខ្ពស់មួយក្នុងការការពារបរិស្ថានទាំងមូល ។

(v) **កិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ** : គឺសំដៅលើការប្រតិបត្តិនូវការរួមបញ្ចូលគ្នានូវវិធានការ និងយុទ្ធសាស្ត្រក្នុងការត្រួតពិនិត្យបរិស្ថានដ៏សមស្រប ។

(vi) **ប្រភពថ្មី** : គឺសំដៅលើប្រភពណាមួយដែលការសាងសង់ ឬការកែលំអត្រូវបានចាប់ផ្តើមឡើងក្នុងរយៈពេលតិចជាង ១ ឆ្នាំក្រោយកាលបរិច្ឆេទនៃ :

- ការចូលជាធរមាននៃអនុសញ្ញានេះសំរាប់ភាគីជាសមាជិកដែលពាក់ព័ន្ធ ។
- ការចូលជាធរមានសំរាប់ភាគីសមាជិក ដែលពាក់ព័ន្ធការធ្វើវិសោធនកម្មឧបសម្ព័ន្ធ (គ) ដែលប្រភពនោះស្ថិតនៅក្រោមបទបញ្ញត្តិនៃអនុសញ្ញានេះដោយអាស្រ័យទៅតាមការធ្វើវិសោធនកម្មនោះ ។

ង - តំលៃកំរិតកំណត់ការសាយភាយឬស្តង់ដារ អាចត្រូវបានប្រើដោយភាគីសមាជិក ដើម្បីបំពេញនូវការប្រតិបត្តិរបស់គេសំរាប់បច្ចេកទេសដ៏ប្រសើរដែលអាចរកបានក្រោមវាក្យខ័ណ្ឌនេះ ។

**មាត្រា ៦ : វិធានការកាត់បន្ថយ ឬបំបាត់ការសាយភាយចេញពីផលិតផលក្នុងស្តុក និងសំណល់**

១- ដើម្បីធានាថា ផលិតផលក្នុងស្តុកដែលធាតុបន្សំរបស់វា ឬមានផ្ទុកសារធាតុគីមី ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ (ក) ឬ ឧបសម្ព័ន្ធ (ខ) និងសំណល់ដែលរួមបញ្ចូលនូវផលិតផល ឬសំភារៈដែលនឹងក្លាយទៅជាសំណល់ដែលមានធាតុផ្សំរបស់វា ឬមានផ្ទុក ឬដែលមានប្រឡាក់ដោយសារធាតុគីមី ដូចដែលមានចែងនៅក្នុងឧបសម្ព័ន្ធ (ក) ឧបសម្ព័ន្ធ (ខ) ឬ ឧបសម្ព័ន្ធ (គ) ត្រូវបានគ្រប់គ្រងតាមវិធីមួយដែលការពារដល់សុខភាពសាធារណៈនិងបរិស្ថាន ភាគីជាសមាជិកនិមួយៗ ត្រូវ :

ក- រៀបចំយុទ្ធសាស្ត្រសមស្របសំរាប់ធ្វើការកំណត់ :

(i) ផលិតផលក្នុងស្តុកដែលធាតុបន្សំរបស់វា ឬមានផ្ទុកសារធាតុគីមីដែលចែងនៅក្នុងឧបសម្ព័ន្ធ (ក) ឬ ឧបសម្ព័ន្ធ (ខ) ។

(ii) ផលិតផល និងសំភារៈដែលកំពុងប្រើប្រាស់ និងសំណល់ដែលមានធាតុបន្សំ ឬមានផ្ទុក ឬដែលមានប្រឡាក់ដោយសារធាតុគីមី ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ (ក) ឧបសម្ព័ន្ធ (ខ) ឬ ឧបសម្ព័ន្ធ (គ) ។

ខ- ធ្វើការកំណត់ផលិតផលក្នុងស្តុកដែលធាតុបន្សំរបស់វា ឬមានផ្ទុកសារធាតុគីមីដែលមានចែងនៅក្នុងឧបសម្ព័ន្ធ (ក) ឬ ឧបសម្ព័ន្ធ (ខ) លើមូលដ្ឋានយុទ្ធសាស្ត្រដូចមានចែងនៅក្នុងកថាខ័ណ្ឌ (ក) ។

គ- គ្រប់គ្រងផលិតផលក្នុងស្តុកតាមវិធីសាស្ត្រប្រកបដោយសុវត្ថិភាព ប្រសិទ្ធិភាព និងបរិស្ថានប្រសើរ។ ផលិតផលក្នុងស្តុកនៃសារធាតុគីមីដូចមានចែងនៅក្នុងឧបសម្ព័ន្ធ (ក) ឬ ឧបសម្ព័ន្ធ (ខ) ដែលវានឹងមិនអនុញ្ញាតឱ្យប្រើប្រាស់ក្នុងរយៈពេលវែងតទៅទៀត ដោយយោងទៅលើករណីលើកលែងពិសេស ដូចបានបញ្ជាក់ក្នុងឧបសម្ព័ន្ធ (ក) ឬករណីលើកលែងពិសេស ឬគោលបំណងដែលអាចទទួលយកបានដែលចែងក្នុងឧបសម្ព័ន្ធ (ខ) លើកលែងតែផលិតផលក្នុងស្តុកដែលត្រូវបានអនុញ្ញាតឱ្យនាំចេញដូចមានចែងនៅក្នុងវាក្យខ័ណ្ឌ ២ នៃមាត្រា ៣ ត្រូវបានចាត់ទុកជាសំណល់ និងត្រូវបានគ្រប់គ្រងដោយអនុលោមទៅតាមកថាខ័ណ្ឌ (ឃ) ។

ឃ- ចាត់វិធានការសមស្រប ដើម្បីឱ្យសំណល់ដោយរាប់បញ្ចូលទាំងផលិតផល និងសំភារៈដែលនឹងក្លាយទៅជាសំណល់ ត្រូវបាន :

(i) ប្រើប្រាស់ ប្រមូល ដឹកជញ្ជូន និងស្តុកទុកតាមវិធីមួយប្រកបដោយសុវត្ថិភាពបរិស្ថាន ។

(ii) បោះបង់ចោលតាមវិធីមួយ ដែលសមាសធាតុនៃសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុត្រូវបានបំផ្លាញ ឬត្រូវបានបំលែងទាំងស្រុង ដែលធ្វើឱ្យសារធាតុទាំងអស់នោះ

មិនអាចមានលក្ខណៈជាសារធាតុពុលសរីរាង្គមិនងាយបំបែកធាតុ ឬការបោះបង់ចោល នៅក្នុងវិធីមួយប្រកបដោយសុវត្ថិភាពបរិស្ថាន នៅពេលដែលការបំផ្លាញឬការបំលែងទាំងស្រុងមិនបង្កនូវបញ្ហាបរិស្ថាន ឬសមាសធាតុនៃសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុមានកំរិតទាប ដោយយកចិត្តទុកដាក់ពីច្បាប់ បទដ្ឋាន គោលការណ៍ណែនាំ និងស្តង់ដារអន្តរជាតិនានា ដោយរួមបញ្ចូលនូវបទបញ្ញត្តិទាំងឡាយណាដែលត្រូវបានបង្កើតឡើង ដោយអនុលោមទៅតាមវាក្យខ័ណ្ឌ ២ ខាងក្រោម និងច្បាប់តំបន់ និងសកលនានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

(iii) មិនអនុញ្ញាតឱ្យអនុវត្តនូវដំណើរការបោះបង់ចោល ដែលអាចនាំឱ្យមានការទាញយកមកប្រើឡើងវិញ ការកែច្នៃឡើងវិញ ការប្រើប្រាស់ដោយផ្ទាល់ឡើងវិញ ឬការប្រើប្រាស់ដោយជំរើសយកសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ។

(iv) មិនអនុញ្ញាតដឹកជញ្ជូនឆ្លងដែនអន្តរជាតិ ដោយគ្មានការអនុលោមច្បាប់បទដ្ឋាន និងគោលការណ៍ណែនាំ និងស្តង់ដារអន្តរជាតិនានាដែលពាក់ព័ន្ធបានឡើយ ។

ង- ធ្វើការប្រឹងប្រែងដើម្បីរៀបចំនូវយុទ្ធសាស្ត្រសមស្របនានា សំរាប់ធ្វើការកំណត់ទីកន្លែងដែលទទួលរងការបំពុលដោយសារធាតុគីមីដូចចែងក្នុងឧបសម្ព័ន្ធ (ក) ឧបសម្ព័ន្ធ(ខ) ឬ ឧបសម្ព័ន្ធ(គ) ។ ប្រសិនបើការស្តារគុណភាពនៅទីកន្លែងនោះត្រូវអនុវត្តន៍ គឺត្រូវដំណើរការតាមវិធីមួយដែលធានានូវសុវត្ថិភាពបរិស្ថាន ។

២- សន្និបាតភាគី ត្រូវសហការណ៍យ៉ាងជិតស្និទ្ធិជាមួយគណៈកម្មាធិការអនុសញ្ញាបាសែល ស្តីពី ចលនាឆ្លងដែននៃសំណល់ប្រកបដោយគ្រោះថ្នាក់ និងការបោះបង់ចោល ដើម្បី :

(i) បង្កើតកំរិតនៃការបំផ្លាញនិងការបំលែងទាំងស្រុងដ៏ចាំបាច់ ដើម្បីធានាថាលក្ខណៈនៃសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដូចដែលមានចែងនៅក្នុងវាក្យខ័ណ្ឌ ១ នៃឧបសម្ព័ន្ធ (ឃ) មិនត្រូវបានបង្ហាញ។

(ii) កំណត់នូវអ្វីដែលត្រូវចាត់ទុកថាជាវិធីបោះបង់ចោលប្រកបដោយសុវត្ថិភាពបរិស្ថាន ដោយយោងទៅចំនុចខាងលើ។

(iii) ធ្វើការបង្កើតកំរិតកំហាប់នៃសារធាតុគីមី ដូចចែងក្នុងឧបសម្ព័ន្ធ (ក) ឧបសម្ព័ន្ធ (ខ) និង ឧបសម្ព័ន្ធ (គ) ក្នុងករណីចាំបាច់ ដើម្បីកំណត់ឱ្យមានកំរិតទាបនូវសមាសធាតុនៃសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុដោយអនុលោមទៅតាមវាក្យខ័ណ្ឌ ១ (ឃ) ចំនុចទី (ii) ។

## <u>មាត្រា ៧</u> : ផែនការអនុវត្តន៍

១- ភាគីជាសមាជិកនីមួយៗត្រូវ :

ក- រៀបចំ និងខិតខំប្រតិបត្តិផែនការសំរាប់អនុវត្តន៍នូវកាតព្វកិច្ចរបស់ខ្លួននៅក្រោមអនុសញ្ញានេះ ។

ខ- បញ្ជូនផែនការអនុវត្តន៍របស់ខ្លួនទៅកាន់សន្និបាតភាគីក្នុងរយៈពេល ២ ឆ្នាំ គិតចាប់ពីថ្ងៃចូលជាភាគីសមាជិក ។

គ- ពិនិត្យឡើងវិញ និងកែសំរួលផែនការអនុវត្តន៍របស់ខ្លួនឱ្យបានទៀងទាត់ និងនៅក្នុងវិធីមួយដែលនឹងត្រូវកំណត់ដោយការសំរេចរបស់សន្និបាតភាគី ។

២- ភាគីទាំងអស់ត្រូវសហការណ៍ដោយផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិ អង្គការតំបន់និងអនុតំបន់ និងពិគ្រោះជាមួយអ្នកពាក់ព័ន្ធក្នុងជាតិរបស់ខ្លួន ដោយរួមបញ្ចូលទាំងសហគមន៍ស្ត្រី និងសហគមន៍នានាដែលពាក់ព័ន្ធនឹងសុខភាពកុមារ ដើម្បីជួយសំរួលការរៀបចំ ការអនុវត្តន៍ និងការកែសំរួលនូវផែនការអនុវត្តន៍របស់ខ្លួន ។

៣- ក្នុងករណីចាំបាច់ ភាគីសមាជិកត្រូវខិតខំប្រើប្រាស់និងរៀបចំនូវនិតិវិធី ដើម្បីបញ្ចូលផែនការអនុវត្តន៍ជាតិសំរាប់សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពរបស់ខ្លួន ។

## មាត្រា ៨ : ការបញ្ចូលបញ្ជីសារធាតុគីមីថ្មីនៅក្នុងឧបសម្ព័ន្ធ(ក) ឧបសម្ព័ន្ធ(ខ) និងឧបសម្ព័ន្ធ(គ)

១- ភាគីអាចដាក់ពាក្យស្នើសុំទៅកាន់លេខាធិការដ្ឋាន សំរាប់ការបញ្ចូលបញ្ជីសារធាតុគីមីថ្មីទៅក្នុងឧបសម្ព័ន្ធ (ក) ឧបសម្ព័ន្ធ (ខ) និងឧបសម្ព័ន្ធ (គ) ។ ពាក្យស្នើសុំនោះត្រូវមានរៀបរាប់នូវព័ត៌មានដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធ (ឃ) ។ នៅក្នុងការរៀបចំពាក្យស្នើសុំ ភាគីអាចត្រូវបានជួយដោយភាគីដទៃ ឬពីលេខាធិការដ្ឋាន ។

២- លេខាធិការដ្ឋានត្រូវផ្ទៀងផ្ទាត់ ថាតើពាក្យស្នើសុំនោះមានរៀបរាប់នូវព័ត៌មានដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធ (ឃ) ឬទេ ។ ប្រសិនបើលេខាធិការដ្ឋានឯកភាពថា ពាក្យស្នើសុំនោះមានរៀបរាប់នូវព័ត៌មានដូចបានកំណត់ លេខាធិការដ្ឋានត្រូវបញ្ជូនពាក្យស្នើសុំនោះទៅគណៈកម្មាធិការពិនិត្យពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ។

៣- គណៈកម្មាធិការត្រូវពិនិត្យពាក្យស្នើសុំនោះ និងប្រើប្រាស់នូវល័ក្ខខ័ណ្ឌវិនិច្ឆ័យដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធ (ឃ) តាមវិធីដែលមានតម្លាភាពនិងប្រែប្រួលតាមសភាពជាក់ស្តែង ដោយបញ្ចូលរាល់ព័ត៌មានដែលបានផ្តល់ក្នុងវិធីថ្លឹងថ្លែង និងចំរុះបញ្ចូលគ្នា ។

៤- ប្រសិនបើគណៈកម្មាធិការសំរេចថា :

ក- វាត្រូវបានឆ្លើយតបនឹងល័ក្ខខ័ណ្ឌវិនិច្ឆ័យដែលត្រូវបំពេញ គណៈកម្មាធិការ តាមរយៈលេខាធិការដ្ឋានត្រូវធ្វើការស្នើ និងការវាយតំលៃរបស់គណៈកម្មាធិការទៅគ្រប់ភាគីនិងអ្នកសង្កេតការទាំងអស់ និងត្រូវស្នើពួកគេឱ្យបញ្ជូនព័ត៌មានដែលបានចែងក្នុងឧបសម្ព័ន្ធ (ង) ឬ

ខ- វាមិនត្រូវបានឆ្លើយតបនឹងល័ក្ខខ័ណ្ឌវិនិច្ឆ័យដែលត្រូវបំពេញ គណៈកម្មាធិការ តាមរយៈលេខាធិការដ្ឋានត្រូវជូនដំណឹងទៅគ្រប់ភាគីនិងអ្នកសង្កេតការទាំងអស់ និងធ្វើការស្នើនិងការវាយតំលៃរបស់គណៈកម្មាធិការទៅគ្រប់ភាគីទាំងអស់ ហើយពាក្យស្នើសុំនោះត្រូវបានដកចេញ ។

៥- ភាគីមួយអាចដាក់ពាក្យស្នើសុំជាថ្មីឡើងវិញទៅកាន់គណៈកម្មាធិការ ដែលត្រូវបានដកដោយគណៈកម្មាធិការ អនុលោមតាមវាក្យខ័ណ្ឌ ៤ ។ ការដាក់ពាក្យស្នើសុំជាថ្មីអាចបញ្ចូលរាល់បញ្ហា ព្រមទាំងការបកស្រាយបង្ហាញរបស់ភាគីស្នើសុំ សំរាប់ជាមូលដ្ឋាននៃការពិចារណាបន្ថែមដោយគណៈកម្មាធិការ។ ប្រសិនបើដំណើរការស្របទៅនឹងល័ក្ខខ័ណ្ឌខាងលើហើយ ប៉ុន្តែគណៈកម្មាធិការនៅតែដកការស្នើសុំនោះចេញទៀត ភាគីនោះអាចជំទាស់ការសំរេចចិត្តរបស់គណៈកម្មាធិការ ហើយសន្និបាតភាគីត្រូវពិចារណាបញ្ហានេះនៅក្នុងសម័យប្រជុំលើកក្រោយ ។ ដោយផ្អែកលើល័ក្ខខ័ណ្ឌវិនិច្ឆ័យដូចបានចែងនៅក្នុងឧបសម្ព័ន្ធ (ឃ) និងដោយការពិចារណាលើការវាយតំលៃរបស់គណៈកម្មាធិការ និងពត៌មានបន្ថែមដែលផ្តល់ដោយភាគីណាមួយ ឬអ្នកសង្កេតការណាមួយ សន្និបាតភាគីអាចសំរេចថាពាក្យស្នើសុំនោះគួរដាក់ធ្វើការពិចារណាបន្ត ។

៦- ក្នុងករណីដែលគណៈកម្មាធិការសំរេចថា ល័ក្ខខ័ណ្ឌវិនិច្ឆ័យត្រូវបានបំពេញ ឬសន្និបាតភាគីបានសំរេចថាពាក្យស្នើសុំនោះគួរដាក់ធ្វើការពិចារណាបន្ត គណៈកម្មាធិការត្រូវពិនិត្យឡើងវិញនូវសំណើនោះ ដោយធ្វើការពិចារណាទៅលើពត៌មានពាក់ព័ន្ធបន្ថែមដែលទទួលបាន និងត្រូវរៀបចំធ្វើសេចក្តីព្រាងរបាយការណ៍ពីលក្ខណៈគ្រោះថ្នាក់ដោយអនុលោមទៅតាមឧបសម្ព័ន្ធ (ង) ។ តាមរយៈលេខាធិការដ្ឋាន គណៈកម្មាធិការត្រូវបញ្ជូនសេចក្តីព្រាងរបាយការណ៍នោះទៅគ្រប់ភាគីនិងអ្នកសង្កេតការ ហើយត្រូវប្រមូលអនុសាសន៍បច្ចេកទេសពីពួកគេ និងធ្វើការពិចារណាលើអនុសាសន៍ទាំងនោះដើម្បីបំពេញនូវសេចក្តីព្រាងរបាយការណ៍នោះ ។

៧- ដោយផ្អែកលើមូលដ្ឋាននៃរបាយការណ៍ពីលក្ខណៈគ្រោះថ្នាក់ ដែលរៀបចំឡើងដោយយោងទៅតាមឧបសម្ព័ន្ធ (ង) ប្រសិនបើគណៈកម្មាធិការសំរេចថា :

ក- សារធាតុគីមីគឺទំនងជាបង្កការបំលាស់ទីឆ្ងាយនៅក្នុងបរិស្ថាន ដែលបណ្តាលឱ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពមនុស្ស ឬឥទ្ធិពលអាក្រក់ដល់បរិស្ថាន ដូចដែលសកម្មភាពជាអន្តរជាតិបានតំរូវឱ្យហាមឃាត់ ពាក្យស្នើសុំនោះត្រូវដាក់ពិនិត្យបន្តទៅទៀត។ កង្វះខាតភាពពិតប្រាកដផ្នែកវិទ្យាសាស្ត្រ នឹងមិនត្រូវរារាំងដល់ការពិចារណានៃសំណើនោះឡើយ ។ តាមរយៈលេខាធិការដ្ឋាន គណៈកម្មាធិការត្រូវប្រមូលពត៌មានពីភាគី និងអ្នកសង្កេតការទាំងអស់ដែលពាក់ព័ន្ធទៅនឹងការពិចារណាដូចមានចែងនៅក្នុងឧបសម្ព័ន្ធ (ច) ។ ដោយអនុលោមទៅតាមឧបសម្ព័ន្ធនោះ គណៈកម្មាធិការត្រូវរៀបចំការវាយតំលៃការគ្រប់គ្រងពីលក្ខណៈគ្រោះថ្នាក់ដោយមានបញ្ចូលនូវការវិភាគនៃវិធានការត្រួតពិនិត្យសំរាប់សារធាតុគីមីនោះ ។

ខ- នឹងមិនពិនិត្យបន្តលើសំណើនោះ ដោយតាមរយៈលេខាធិការដ្ឋាន គណៈកម្មាធិការត្រូវបញ្ជូនរបាយការណ៍ពីលក្ខណៈគ្រោះថ្នាក់នោះទៅភាគីនិងអ្នកសង្កេតការទាំងអស់ ហើយត្រូវដកសំណើនោះចេញ ។

៨- ចំពោះសំណើដែលបានដកចេញដូចចែងក្នុងវាក្យខ័ណ្ឌ ៧ (ខ) ភាគីមួយអាចស្នើសុំទៅកាន់សន្និបាតភាគី ដើម្បីធ្វើការពិចារណា ដោយណែនាំទៅគណៈកម្មាធិការឱ្យប្រមូលពត៌មានបន្ថែមពីភាគីដែលបានដាក់ពាក្យសុំ និងភាគីដទៃទៀតក្នុងរយៈពេលមិនលើសពី ១ ឆ្នាំ ។ ក្រោយរយៈនេះ និងដោយផ្អែកលើពត៌មានបន្ថែម ដែលទទួលបាន គណៈកម្មាធិការត្រូវពិចារណាឡើងវិញលើសំណើសុំ ដោយអនុលោមតាមវាក្យខ័ណ្ឌ ៦ ដោយត្រូវចាត់ថាជាអាទិភាពដែលនឹងត្រូវសំរេចដោយសន្និបាតភាគី។ ប្រសិនបើអនុលោមទៅតាមនិតិវិធី ខាងលើនេះហើយ ប៉ុន្តែគណៈកម្មាធិការនៅតែដកសំណើនោះចេញទៀត ភាគីស្នើសុំនោះអាចជំទាស់ការ សំរេចចិត្តរបស់គណៈកម្មាធិការ ហើយសន្និបាតភាគីត្រូវធ្វើការពិចារណាបញ្ហានេះនៅក្នុងសម័យប្រជុំលើក ក្រោយ។ ដោយផ្អែកទៅលើរបាយការណ៍ពីលក្ខណៈគ្រោះថ្នាក់ ដូចដែលបានចែងក្នុងឧបសម្ព័ន្ធ (ង) និងពិចារណាលើការវាយតំលៃរបស់គណៈកម្មាធិការ និងពត៌មានបន្ថែមផ្តល់ដោយភាគីណាមួយ ឬអ្នកសង្កេត ការណាមួយ សន្និបាតភាគីអាចសំរេចថាការស្នើសុំនោះគួរដាក់ធ្វើការពិចារណាជាបន្ត។ ប្រសិនបើ សន្និបាត ភាគីអាចសំរេចថាការស្នើសុំនោះត្រូវដាក់ធ្វើការពិចារណាជាបន្ត បន្ទាប់មកគណៈកម្មាធិការត្រូវរៀបចំការ វាយតំលៃការគ្រប់គ្រងលក្ខណៈគ្រោះថ្នាក់ ។

៩- ដោយផ្អែកលើរបាយការណ៍ពីលក្ខណៈគ្រោះថ្នាក់ដែលចែងក្នុងវាក្យខ័ណ្ឌ ៦ និងការវាយតំលៃការគ្រប់ គ្រងលក្ខណៈគ្រោះថ្នាក់ចែងក្នុងវាក្យខ័ណ្ឌ ៧ (ក) ឬវាក្យខ័ណ្ឌ ៨ គណៈកម្មាធិការត្រូវធ្វើអនុសាសន៍ថា តើសារធាតុគីមីនោះគួរតែ ត្រូវធ្វើការពិចារណាដោយសន្និបាតភាគីសំរាប់ធ្វើការចុះបញ្ជីនៅក្នុងឧបសម្ព័ន្ធ (ក) ឧបសម្ព័ន្ធ (ខ) ឬឧបសម្ព័ន្ធ (គ) ឬយ៉ាងណា។ ដោយការពិចារណាលើអនុសាសន៍របស់គណៈកម្មាធិការ ដោយរួមបញ្ចូលភាពមិនទាន់គ្រប់គ្រាន់នៃវិទ្យាសាស្ត្រ សន្និបាតភាគីត្រូវសំរេចចិត្តធ្វើការចុះបញ្ជីសារធាតុ គីមីនោះ និងធ្វើការកំណត់វិធានការត្រួតពិនិត្យលើសារធាតុគីមីនោះ ដែលចែងនៅក្នុងឧបសម្ព័ន្ធ (ក) ឧបសម្ព័ន្ធ (ខ) ឬ ឧបសម្ព័ន្ធ (គ) ។

**<u>មាត្រា ៩</u> : ការផ្លាស់ប្តូរពត៌មាន**

១- ភាគីនិមួយៗត្រូវសំរបសំរួល ឬទទួលរ៉ាប់រងក្នុងការផ្លាស់ប្តូរពត៌មានដែលទាក់ទងទៅនឹង :

ក- ការកាត់បន្ថយ ឬលុបបំបាត់នូវការផលិត ការប្រើប្រាស់ និងការសាយភាយនូវសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ។

ខ- ការជំរើសប្រើសារធាតុគីមីដទៃជំនួសសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដោយរួមបញ្ចូលពត៌មានទាក់ទងទៅនឹងលក្ខណៈគ្រោះថ្នាក់របស់វា ក៏ដូចជាតំលៃសេដ្ឋកិច្ចនិងសង្គមរបស់វា ។

២- ភាគីទាំងអស់ត្រូវធ្វើការផ្លាស់ប្តូរពត៌មានដែលមានចែងក្នុងវាក្យខ័ណ្ឌ ១ ដោយផ្ទាល់ ឬតាមរយៈលេខាធិការដ្ឋាន។

៣- ភាគីនិមួយៗត្រូវចាត់មន្ត្រីទំនាក់ទំនងម្នាក់ដែលទទួលខុសត្រូវក្នុងការផ្លាស់ប្តូរនូវពត៌មានទាំងនោះ ។

៤- លេខាធិការដ្ឋានត្រូវទទួលបន្ទុកជាយន្តការសំរបសំរួលក្នុងការទទួលនិងផ្សព្វផ្សាយពត៌មានស្តីពី សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដោយរួមបញ្ចូលនូវពត៌មានដែលផ្តល់ដោយភាគីទាំងអស់ ស្ថាប័នអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ។

៥- សំរាប់គោលបំណងនៃអនុសញ្ញានេះ ពត៌មាន ស្តីពី សុខភាពនិងសុវត្ថិភាពរបស់មនុស្សនិងបរិស្ថានមិនត្រូវចាត់ទុកជាការសំងាត់ឡើយ ។ គ្រប់ភាគីដែលផ្លាស់ប្តូរពត៌មានដ៏ទៃផ្សេងទៀត អនុលោមតាមអនុសញ្ញានេះត្រូវការពារនូវពត៌មានសំងាត់ផ្សេងៗ ដូចបានព្រមព្រៀង។

**មាត្រា ១០ : ពត៌មានជាសាធារណៈ ចំណេះដឹង និងការអប់រំ**

១- ភាគីនិមួយៗ តាមលទ្ធភាពរបស់ខ្លួនត្រូវបង្កើន និងសំរបសំរួល :

ក- ការផ្តល់ចំណេះដឹងក្នុងចំណោមអ្នកធ្វើគោលនយោបាយ និងធ្វើការសំរេចចិត្តរបស់គេ អំពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ។

ខ- ការផ្តល់ដល់សាធារណជននូវពត៌មានដែលអាចរកបានស្តីពី សារធាតុបំពុលសរីរាង្គមិនបំបែកធាតុ ដោយរាប់បញ្ចូលនូវអ្វីដែលមានចែងក្នុងវាក្យខ័ណ្ឌ ៥ នៃមាត្រា ៩ ។

គ- ការរៀបចំ និងការអនុវត្តន៍កម្មវិធីអប់រំនិងចំណេះដឹងសាធារណៈ ស្តីពី សារធាតុបំពុលសរីរាង្គមិនបំបែកធាតុ និងពីឥទ្ធិពលគ្រោះថ្នាក់លើសុខភាពរបស់គេនិងទៅលើបរិស្ថាន និងពីការជំរើសសារធាតុគីមីដែលត្រូវប្រើជំនួស ទៅដល់ស្ត្រី កុមារ និងអ្នកដែលបានទទួលការអប់រំតិចតួច។

ឃ- ការចូលរួមរបស់សាធារណជន ក្នុងការគិតគូរដោះស្រាយបញ្ហាសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ និងឥទ្ធិពលរបស់វាលើសុខភាពរបស់ពួកគេនិងទៅលើបរិស្ថាន និងក្នុងការបង្កើតការទទួលខុសត្រូវគ្រប់គ្រាន់ដោយរួមបញ្ចូលនូវឱកាសផ្សេងៗ សំរាប់ផ្តល់លទ្ធភាពកំរិតជាតិក្នុងការអនុវត្តន៍អនុសញ្ញានេះ ។

ង- ការបណ្តុះបណ្តាលកម្មករ អ្នកវិទ្យាសាស្ត្រ អ្នកអប់រំ និងអ្នកបច្ចេកទេសនិងគ្រប់គ្រង។

ច- ការរៀបចំនិងការផ្លាស់ប្តូរឯកសារអប់រំ និងឯកសារចំណេះដឹងសាធារណៈថ្នាក់ជាតិនិងអន្តរជាតិ។

ឆ- ការរៀបចំ និងការប្រតិបត្តិនូវកម្មវិធីអប់រំនិងបណ្តុះបណ្តាលថ្នាក់ជាតិ និងអន្តរជាតិ ។

២- តាមសមត្ថភាពរបស់ខ្លួន ភាគីនីមួយៗត្រូវធ្វើការធានាថា សាធារណជនបានទទួលនូវពត៌មានជាសាធារណៈ ដែលមានចែងក្នុងវាក្យខ័ណ្ឌ ១ និងធានាថាពត៌មានទាំងនោះត្រូវតែលំអទាន់ពេលវេលា ។

៣- តាមសមត្ថភាពរបស់ខ្លួន ភាគីនិមួយៗត្រូវលើកទឹកចិត្តអ្នកប្រើប្រាស់វិជ្ជាជីវៈ និងផ្នែកឧស្សាហកម្ម ដើម្បីជំរុញនិងសំរបសំរួលការផ្តល់ឱ្យនូវពត៌មាន ដែលមានចែងក្នុងវាក្យខ័ណ្ឌ ១ នៅកំរិតជាតិ និងបើអាចទៅរួចបន្តទៅកំរិតអនុតំបន់ តំបន់ និងអន្តរជាតិ។

៤- ក្នុងការផ្តល់ព័ត៌មាន ស្តីពី សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុនិងជំរើសប្រើជំនួសរបស់គេ ភាគីទាំងអស់អាចប្រើប្រាស់តារាងទិន្នន័យសុវត្ថិភាព របាយការណ៍ ប្រព័ន្ធផ្សព្វផ្សាយ និងមធ្យោបាយផ្សេងទៀតក្នុងការទំនាក់ទំនង និងអាចបង្កើតមជ្ឈមណ្ឌលព័ត៌មានថ្នាក់ជាតិ និងតំបន់។

៥- ភាគីនីមួយៗត្រូវយកចិត្តទុកដាក់ដើម្បីបង្កើតយន្តការ ដូចជា ការចុះបញ្ជីការដឹកជញ្ជូន និងការសាយភាយសារធាតុបំពុល សំរាប់ការប្រមូលនិងការផ្សព្វផ្សាយនូវព័ត៌មាន ស្តីពី ការប៉ាន់ប្រមាណប្រចាំឆ្នាំនៃសារធាតុគីមី ដែលបានចុះបញ្ជីនៅក្នុងឧបសម្ព័ន្ធ (ក) ឧបសម្ព័ន្ធ (ខ) ឬ ឧបសម្ព័ន្ធ (គ) ដែលត្រូវបានបញ្ចេញចោល ឬបោះបង់ចោល ។

## មាត្រា ១១ : ការស្រាវជ្រាវ ការអភិវឌ្ឍន៍ និងការត្រួតពិនិត្យ

១- តាមសមត្ថភាពរបស់ខ្លួននៅថ្នាក់ជាតិ និងអន្តរជាតិ ភាគីទាំងអស់ត្រូវតែលើកទឹកចិត្ត ឬទទួលរ៉ាប់រងធ្វើការស្រាវជ្រាវ ការអភិវឌ្ឍន៍ ការត្រួតពិនិត្យនិងកិច្ចសហប្រតិបត្តិការដែលអាចធ្វើទៅបាន ដែលទាក់ទងទៅនឹងសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ និងការប្រើជំរើសជំនួសរបស់វា រួមមាន :

ក- ប្រភព និងការសាយភាយទៅក្នុងបរិស្ថាន

ខ- វត្តមាន កំរិត និងនិន្នាការក្នុងខ្លួនមនុស្ស និងក្នុងបរិស្ថាន

គ- ការបំលាស់ទីក្នុងបរិស្ថាន ការវិវឌ្ឍន៍ និងការប្រែប្រួល

ឃ- ឥទ្ធិពលលើសុខភាពមនុស្ស និងបរិស្ថាន

ង- ផលប៉ះពាល់លើសេដ្ឋកិច្ចសង្គម និងវប្បធម៌

ច- ការកាត់បន្ថយ ឬការលុបបំបាត់ការសាយភាយ និង

ឆ- វិធីសាស្ត្រចំរុះដើម្បីធ្វើសារពើភ័ណ្ឌលើប្រភពបង្កើត និងបច្ចេកទេសវិភាគសំរាប់ការវាស់ស្ទង់នូវការសាយភាយ ។

២- នៅក្នុងសកម្មភាពទទួលខុសត្រូវនៅក្រោមវាក្យខ័ណ្ឌ ១ តាមសមត្ថភាពរបស់ខ្លួន ភាគីទាំងអស់ត្រូវ :

ក- គាំទ្រ និងអភិវឌ្ឍន៍បន្ថែមទៀតនូវកម្មវិធីអន្តរជាតិ បណ្តាញការងារ និងអង្គការផ្សេងទៀតក្នុងគោលបំណងធ្វើការកំណត់ និងការអនុវត្តន៍ការវាយតំលៃ ការផ្តល់ថវិកាស្រាវជ្រាវ ការប្រមូលនិងត្រួតពិនិត្យទិន្នន័យ ដោយពិចារណាតំរូវការដើម្បីបន្ថយភាពជាន់គ្នានៃកិច្ចខិតខំប្រឹងប្រែង។

ខ- គាំទ្រការខិតខំប្រឹងប្រែងកំរិតជាតិ និងអន្តរជាតិដើម្បីពង្រឹងសមត្ថភាពអ្នកវិទ្យាសាស្ត្រជាតិ និងសមត្ថភាពស្រាវជ្រាវបច្ចេកទេស ជាពិសេសនៅប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលសេដ្ឋកិច្ចអន្តរកាល និងដើម្បីជំរុញឱ្យឈានទៅទទួលបាននូវការផ្លាស់ប្តូរទិន្នន័យ និងការវិភាគ ។

គ- យកចិត្តទុកដាក់ដល់កង្វល់ និងតម្រូវការចាំបាច់ ជាពិសេសក្នុងផ្នែកថវិកា និងធនធានបច្ចេកទេស របស់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល និងសហប្រតិបត្តិការក្នុង ការពង្រីកសមត្ថភាពរបស់ពួកគេដើម្បីចូលរួមក្នុងការប្រឹងប្រែង ដែលមានចែងក្នុងវាក្យខ័ណ្ឌ ក និងវាក្យខ័ណ្ឌ ខ ។

ឃ- ទទួលរ៉ាប់រងការងារស្រាវជ្រាវឆ្ពោះទៅរកការកាត់បន្ថយឥទ្ធិពលរបស់សារធាតុបំពុលសរីរាង្គមិន ងាយបំបែកធាតុលើសុខភាពបង្កកំណើត ។

ង- ចងក្រងលទ្ធផលនៃសកម្មភាពស្រាវជ្រាវ អភិវឌ្ឍន៍និងត្រួតពិនិត្យរបស់ពួកគេ ដែលមានចែងក្នុង វាក្យខ័ណ្ឌនេះ ដោយធ្វើឱ្យបានទៅដល់សាធារណជនទាន់ពេលវេលា និងទៀងទាត់ ។

ច- លើកទឹកចិត្ត ឬទទួលរ៉ាប់រងសហប្រតិបត្តិការលើការរក្សាទុកនិងការថែទាំនូវពត៌មាន ដែលបាន មកពីការស្រាវជ្រាវ ការអភិវឌ្ឍន៍ និងការត្រួតពិនិត្យ ។

**មាត្រា ១២ : ជំនួយបច្ចេកទេស**

១- ភាគីទាំងអស់ទទួលស្គាល់ថា ការផ្តល់ជំនួយបច្ចេកទេសសមស្របនិងទាន់ពេលវេលា ក្នុងការឆ្លើយតប ទៅនឹងសំណូមពរពីភាគីជាប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីជាប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល គឺជាការ ចាំបាច់ដើម្បីអនុវត្តន៍អនុសញ្ញានេះឱ្យបានជោគជ័យ ។

២- ភាគីទាំងអស់ត្រូវសហការណ៍ផ្តល់ជំនួយបច្ចេកទេសសមស្របនិងទាន់ពេលវេលា ទៅឱ្យភាគីជាប្រទេស កំពុងអភិវឌ្ឍន៍ និងភាគីដែលជាប្រទេសមានសេដ្ឋកិច្ចអន្តរកាលសំរាប់ជួយពួកគេ ដោយគិតគូរទៅដល់តម្រូវ ការចាំបាច់របស់គេ ដើម្បីអភិវឌ្ឍន៍និងពង្រឹងសមត្ថភាពក្នុងការអនុវត្តន៍កាតព្វកិច្ចនៅក្រោមអនុសញ្ញានេះ ។

៣- ចំពោះបញ្ហានេះ ជំនួយបច្ចេកទេសនឹងត្រូវបានផ្តល់ដោយភាគីដែលជាប្រទេសអភិវឌ្ឍន៍ និងភាគីផ្សេង ទៀតទៅតាមសមត្ថភាពរបស់គេ ដោយផ្អែកតាមការយល់ព្រមទៅវិញទៅមក ត្រូវរួមបញ្ចូលនូវជំនួយបច្ចេក ទេសសំរាប់កសាងសមត្ថភាព ដែលទាក់ទងទៅនឹងការអនុវត្តន៍នូវកាតព្វកិច្ចក្រោមអនុសញ្ញានេះ ។ ការណែនាំ បន្ថែមចំពោះបញ្ហានេះ នឹងត្រូវបានផ្តល់ដោយសន្និបាតភាគីជាសមាជិក ។

៤- ភាគីទាំងអស់ត្រូវបង្កើតនូវការរៀបចំផ្សេងៗ ក្នុងគោលបំណងផ្តល់ជំនួយបច្ចេកទេស និងជំរុញការផ្ទេរ បច្ចេកវិជ្ជាទៅភាគីជាប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីជាប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល ដែលទាក់ទងនឹង ការអនុវត្តន៍អនុសញ្ញានេះ ។ ការរៀបចំទាំងនោះ ត្រូវរួមបញ្ចូលមជ្ឈមណ្ឌលថ្នាក់តំបន់ និងថ្នាក់អនុតំបន់ សំរាប់ការកសាងសមត្ថភាព និងការផ្ទេរបច្ចេកវិជ្ជាដើម្បីជួយភាគីជាប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីជា ប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល ដើម្បីបំពេញកាតព្វកិច្ចរបស់គេក្រោមអនុសញ្ញានេះ ។ ការណែនាំបន្ថែម លើបញ្ហានេះ នឹងត្រូវបានផ្តល់ដោយសន្និបាតភាគីជាសមាជិក ។

៥- ក្នុងបរិបទនៃមាត្រានេះ ភាគីទាំងអស់ត្រូវយកចិត្តទុកដាក់នូវតម្រូវការដ៏ជាក់លាក់ និងស្ថានការណ៍ពិសេសរបស់ប្រទេសដែលការអភិវឌ្ឍន៍មានកំរិតទាប និងរដ្ឋកំពុងអភិវឌ្ឍន៍នៅតាមកោះតូចៗ នៅក្នុងសកម្មភាពរបស់គេផ្នែកជំនួយបច្ចេកទេស ។

## មាត្រា ១៣ : ធនធានថវិកា និងយន្តការ

១- តាមសមត្ថភាព ភាគីនិមួយៗទទួលរ៉ាប់រងផ្តល់ជំនួយជាថវិកា និងការលើកទឹកចិត្តចំពោះរាល់សកម្មភាពជាតិ ដែលមានគោលបំណងដើម្បីសំរេចបាននូវកម្មវត្ថុរបស់អនុសញ្ញានេះ អនុលោមទៅតាមផែនការ បញ្ហាអាទិភាព និងកម្មវិធីផ្សេងៗទៀតរបស់ជាតិផ្ទាល់ ។

២- ភាគីជាប្រទេសអភិវឌ្ឍន៍ ត្រូវផ្តល់នូវធនធានថវិកាថ្មីនិងបន្ថែមទៀត ដើម្បីជួយឱ្យភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីជាប្រទេសមានសេដ្ឋកិច្ចអន្តរកាល ទទួលបានពេញលេញនូវតំលៃបន្ថែមលើវិធានការអនុវត្តន៍ សំរាប់បំពេញកាតព្វកិច្ចនៅក្រោមអនុសញ្ញានេះ ដូចដែលបានយល់ព្រមរវាងភាគីទទួល និងអង្គភាពចូលរួមក្នុងយន្តការដូចរៀបរាប់ក្នុងវាក្យខ័ណ្ឌ ៦ ។ ភាគីផ្សេងទៀត ដោយផ្អែកលើមូលដ្ឋានស្ម័គ្រចិត្ត និងអនុលោមទៅតាមសមត្ថភាពរបស់គេ ក៏អាចផ្តល់នូវថវិកានេះបានដែរ ។ ការធ្វើវិភាគទានពីប្រភពផ្សេងៗទៀត ក៏ត្រូវបានលើកទឹកចិត្តផងដែរ ។ ការអនុវត្តចំពោះកិច្ចសន្យាទាំងនោះ ត្រូវយកចិត្តទុកដាក់ពីតំរូវការឱ្យមានភាពគ្រប់គ្រាន់ ភាពរំពឹងទុក ការផ្តល់ថវិកាទាន់ពេលវេលា និងសារៈប្រយោជន៍នៃការរួមចំណែករបស់ភាគីដែលធ្វើវិភាគទាន ។

៣- ភាគីជាប្រទេសអភិវឌ្ឍន៍ និងភាគីផ្សេងទៀត តាមសមត្ថភាពរបស់គេនិងអនុលោមទៅតាមផែនការជាតិ អាទិភាព និងកម្មវិធីផ្សេងៗ អាចផ្តល់ផងដែរដល់ភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីជាប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល នូវធនធានថវិកាដែលអាចរកបាន ដើម្បីជួយគេក្នុងការអនុវត្តន៍អនុសញ្ញានេះតាមរយៈឧបតេភាគី តំបន់ និងប្រភពភាគីច្រើន ឬបណ្តាញផ្សេងៗ ។

៤- ការអនុវត្តន៍កាតព្វកិច្ចរបស់ភាគីជាប្រទេសកំពុងអភិវឌ្ឍន៍នៅក្រោមអនុសញ្ញានេះ នឹងមានប្រសិទ្ធិភាព គឺអាស្រ័យលើការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព របស់ភាគីជាប្រទេសអភិវឌ្ឍន៍នូវកាតព្វកិច្ចរបស់គេក្រោមអនុសញ្ញានេះដែលទាក់ទងទៅនឹងធនធានថវិកា ជំនួយបច្ចេកទេសនិងការផ្ទេរបច្ចេកវិជ្ជាផងដែរ ។ ហេតុការណ៍ដែលការអភិវឌ្ឍន៍ សេដ្ឋកិច្ច និងសង្គម និងការលុបបំបាត់នូវភាពក្រីក្រ គឺជាអាទិភាពទីមួយ និងដែលត្រូវសំរេចជោគជ័យរបស់ភាគីជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលត្រូវយកចិត្តទុកដាក់លើតំរូវការសំរាប់កិច្ចការពារសុខភាពមនុស្សជាតិ និងបរិស្ថាន ។

៥- ភាគីទាំងអស់ត្រូវគិតគូរឱ្យបានគ្រប់គ្រាន់ នូវតំរូវការជាក់លាក់និងស្ថានភាពពិសេសនៃប្រទេសដែលមានការអភិវឌ្ឍន៍ទាប និងរដ្ឋកំពុងអភិវឌ្ឍន៍នៅតាមកោះ នៅក្នុងសកម្មភាពរបស់គេចំពោះបញ្ហាថវិកា ។

៦- យន្តការមួយសំរាប់ផ្តល់ធនធានថវិកាឱ្យបានគ្រប់គ្រាន់និងដោយនិរន្តរភាព ដល់ប្រទេសដែលកំពុងអភិវឌ្ឍន៍ និងប្រទេសដែលសេដ្ឋកិច្ចស្ថិតក្នុងភាពអន្តរកាល លើមូលដ្ឋានជំនួយ ឬឱ្យខ្ចី ដើម្បីជួយគេក្នុងការអនុវត្តន៍អនុសញ្ញាដូចដែលបានចែង ។ យន្តការនេះនឹងដំណើរការនៅបានក្រោមអំណាច និងការណែនាំ ហើយនឹងត្រូវបានដាក់ឱ្យទទួលអនុវត្តនៅពេលប្រជុំភាគីតាមគោលបំណងរបស់អនុសញ្ញានេះ ។ ប្រតិបត្តិការរបស់គេត្រូវបានប្រគល់ឱ្យអង្គភាពមួយ ឬច្រើនទៀត ដោយរាប់បញ្ចូលទាំងអង្គភាពអន្តរជាតិដែលមានស្រាប់ដូចដែលបានសំរេចដោយសន្និបាតភាគី ។ យន្តការនេះក៏អាចបញ្ចូលនូវអង្គភាពផ្សេងៗ ដែលផ្តល់ជំនួយបច្ចេកទេស និងថវិកា ដោយឧបតោភាគី តំបន់ និងភាគីជាច្រើនទៀត ។ វិភាគទានសំរាប់យន្តការនេះនឹងត្រូវបន្ថែមទៅការផ្ទេរថវិកាផ្សេងសំរាប់ភាគីជាប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីជាប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល ដូចដែលបានគិតយោងទៅតាមវាក្យខ័ណ្ឌ ២ ។

៧- យោងទៅតាមគោលដៅរបស់អនុសញ្ញានេះ និងវាក្យខ័ណ្ឌ ៦ សន្និបាតភាគីលើកទី ១ ត្រូវតែអនុម័តគោលការណ៍ណែនាំដ៏សមស្រប ដើម្បីផ្តល់ដល់យន្តការ និងត្រូវយល់ព្រមជាមួយអង្គភាពមួយ ឬច្រើនក្នុងការចូលរួមនៅក្នុងយន្តការថវិកា លើការរៀបចំដើម្បីឱ្យមានប្រសិទ្ធភាពនៅទីនោះ ។ ការណែនាំត្រូវតែបង្ហាញនូវទំនាក់ទំនងគ្នាទៅវិញទៅមកនូវ :

ក- ការកំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីអាទិភាព ក៏ដូចជាគោលការណ៍ណែនាំ និងល័ក្ខខ័ណ្ឌ ដែលមានលក្ខណៈលំអិត និងច្បាស់លាស់ ទាក់ទងភាពដែលអាចទទួលបាន និងប្រើប្រាស់ធនធានថវិកា ដោយគិតបញ្ចូលទាំងការត្រួតពិនិត្យ និងការវាយតំលៃលើមូលដ្ឋានត្រឹមត្រូវនៃការប្រើប្រាស់នោះ ។

ខ- ការផ្តល់ដោយអង្គភាពមួយ ឬអង្គភាពច្រើននូវរបាយការណ៍ជាប្រចាំទៅសន្និបាតភាគី ពីភាពគ្រប់គ្រាន់និងដោយនិរន្តរភាពនៃថវិកា សំរាប់សកម្មភាពទាក់ទងទៅនឹងការអនុវត្តន៍អនុសញ្ញានេះ ។

គ- ការបង្កើនការរៀបចំយន្តការ និងដំណោះស្រាយប្រភពផ្តល់ថវិកាចំរុះ ។

ឃ- បែបបទសំរាប់ធ្វើការកំណត់របៀបប៉ាន់ស្មានចំនួនថវិកាត្រូវការ និងដែលអាចរកបានសំរាប់ការអនុវត្តន៍អនុសញ្ញានេះ ។ ហើយត្រូវចាំទុកថា លទ្ធផលនៃការលុបចំបាត់នូវសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុអាចត្រូវការនូវការផ្តល់ថវិកាជាបន្តបន្ទាប់ និងល័ក្ខខ័ណ្ឌដែលជាចំនួនថវិកានឹងត្រូវបានធ្វើការពិនិត្យឡើងវិញ ។

ង- របៀបរបបសំរាប់ផ្តល់ដល់ភាគីសាម៉ី (ភាគីផ្តល់ជំនួយ) នូវការជួយដែលត្រូវវាយតំលៃ និងពត៌មានពីប្រភពថវិកាដែលអាចរកបាន និងរបៀបផ្តល់ថវិកា ដើម្បីសម្រួលការសហការក្នុងចំណោមពួកគេ ។

៨- មិនត្រូវឱ្យយឺតជាងការប្រជុំលើកទី២ និងជាបន្តមកទៀត សន្និបាតរបស់ភាគីត្រូវពិនិត្យសារឡើងវិញនូវប្រសិទ្ធិភាពរបស់យន្តការ ដែលបានបង្កើតឡើងក្រោមមាត្រានេះ ហើយពិនិត្យលទ្ធភាពរបស់យន្តការនេះ ដើម្បីបង្ហាញ ពីការប្រែប្រួលតម្រូវការរបស់ភាគី ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងដែលមានសេដ្ឋកិច្ចអន្តរកាល និងពិនិត្យនូវល័ក្ខខ័ណ្ឌ និងការណែនាំ យោងតាមវាក្យខ័ណ្ឌ ៧ ហើយនឹងពិនិត្យនូវកំរិតនៃការផ្តល់ថវិកា ក៏ដូចជាប្រសិទ្ធិភាព នៃការអនុវត្តរបស់អង្គភាពដែលបានប្រគល់ឱ្យដើម្បីដំណើរការយន្តការថវិកា ។ ដោយផ្អែកលើការពិនិត្យឡើងវិញ យន្តការនេះត្រូវធ្វើសកម្មភាពសមស្របមួយ ប្រសិនជាការចាំបាច់ដើម្បីបង្កើននូវប្រសិទ្ធភាពរបស់យន្តការនេះ ដោយរួមបញ្ចូលនូវមធ្យោបាយក្នុងការផ្តល់សំណូមពរ និងការណែនាំលើវិធានការដើម្បីធានាការផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់ និងមាននិរន្តរភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ភាគី ។

**<u>មាត្រា ១៤</u> : ការរៀបចំថវិកាបណ្តោះអាសន្ន**

ដោយផ្អែកទៅលើមូលដ្ឋានបណ្តោះអាសន្ន រចនាសម្ព័ន្ធនៃស្ថាប័នមូលនិធិបរិស្ថានពិភពលោក (GEF) ដែលដំណើរការដោយអនុលោមទៅតាមបរិធានសំរាប់ការបង្កើតនូវការកែសំរួលរចនាសម្ព័ន្ធឡើងវិញរបស់មូលនិធិបរិស្ថានពិភពលោក គឺត្រូវបានចាត់ទុកជាអង្គភាពសំខាន់មួយ ដែលទទួលដំណើរការយន្តការថវិកាអនុលោមទៅតាមមាត្រា ១៣ សំរាប់រយៈពេលចាប់ពីថ្ងៃចូលជាធរមាននៃ អនុសញ្ញានេះទៅដល់ការប្រជុំលើកទី ១ នៃសន្និបាតភាគី ឬរហូតដល់ពេលដែលសន្និបាតភាគីសំរេចលើរចនាសម្ព័ន្ធស្ថាប័នណាមួយដែលនឹងត្រូវបានចាត់តាំងឡើងយោងតាមមាត្រា ១៣ ។ រចនាសម្ព័ន្ធ ស្ថាប័នមូលនិធិបរិស្ថានពិភពលោកត្រូវបំពេញតួនាទីតាមរយៈវិធានការដំណើរការដែលជាប់ទាក់ទង ជាពិសេសចំពោះសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដោយគិតរួមបញ្ចូលថាការរៀបចំថ្មីសំរាប់ផ្នែកនេះគួរតែត្រូវមាន ។

**<u>មាត្រា ១៥</u> : របាយការណ៍**

១- ភាគីនីមួយៗត្រូវធ្វើរបាយការណ៍ទៅសន្និបាតភាគី ពីវិធានការដែលគេបានដាក់ចេញដើម្បីអនុវត្តន៍នូវបទបញ្ញត្តិនៃអនុសញ្ញានេះ និងពីប្រសិទ្ធភាពនៃវិធានការនេះ ដើម្បីឆ្លើយតបនឹងគោលបំណងរបស់អនុសញ្ញានេះ ។

២- ភាគីនីមួយៗ ត្រូវផ្តល់ទៅលេខាធិការដ្ឋាននូវ :

ក- ស្ថិតិទិន្នន័យលើបរិមាណសរុបនៃការផលិត ការនាំចូល និងការនាំចេញនូវសារធាតុគីមីនីមួយៗ ដែលបានចុះបញ្ជីនៅក្នុងឧបសម្ព័ន្ធ ( ក) និង ឧបសម្ព័ន្ធ (ខ) ឬប៉ាន់ប្រមាណឱ្យបានសមស្របនូវទិន្នន័យនេះ ។

ខ- បញ្ជីឈ្មោះប្រទេសដែលពីប្រទេសនោះសារធាតុគីមីត្រូវបាននាំចូល និងឈ្មោះប្រទេសដែលទៅប្រទេសនោះសារធាតុគីមីត្រូវបានធ្វើការនាំចេញ ។

៣- របាយការណ៍នេះត្រូវធ្វើឡើងក្នុងចន្លោះពេលកំណត់មួយ នៅក្នុងទំរង់ដែលត្រូវបានសំរេចដោយសន្និបាតភាគីនៅកិច្ចប្រជុំលើកទី ១ ។

**មាត្រា ១៦ : ការវាយតំលៃប្រសិទ្ធិភាពអនុវត្តន៍**

១- បួនឆ្នាំបន្ទាប់ពីថ្ងៃដែលបានចូលជាធរមាននៃអនុសញ្ញានេះ និងចន្លោះពេលបន្ទាប់មកដែលនឹងត្រូវបានសំរេចដោយសន្និបាតភាគី សន្និបាតត្រូវធ្វើការវាយតំលៃប្រសិទ្ធិភាពអនុវត្តន៍របស់អនុសញ្ញានេះ ។

២- ដើម្បីផ្តល់ភាពងាយស្រួលដល់ការវាយតំលៃ សន្និបាតភាគីលើកទី ១ ត្រូវផ្តួចផ្តើមធ្វើការបង្កើតនូវបែបបទដើម្បីផ្តល់ការប្រៀបធៀបទិន្នន័យត្រួតពិនិត្យពីវត្តមានសារធាតុគីមី ដែលបានចុះបញ្ជីនៅក្នុងឧបសម្ពន្ធ (ក) ឧបសម្ពន្ធ (ខ) និងឧបសម្ពន្ធ (គ) ក៏ដូចជាចលនាក្នុងបរិស្ថាន និងតំបន់ដែរ ។ បែបបទនេះ :

- ក- នឹងត្រូវអនុវត្តន៍ដោយភាគីលើមូលដ្ឋានតំបន់ ដោយអនុលោមទៅតាមសមត្ថភាពបច្ចេកវិជ្ជា និងលទ្ធភាពថវិកា ដែលប្រើប្រាស់កម្មវិធីនិងយន្តការត្រួតពិនិត្យដែលមានស្រាប់ឱ្យទូលំទូលាយ និងធ្វើឱ្យប្រសើរវិធីសាស្ត្រដែលស្របគ្នា ។
- ខ- អាចនឹងត្រូវបន្ថែមបើសិនជាចាំបាច់ដោយគិតពិចារណាពីភាពផ្សេងគ្នារវាងតំបន់ និងសមត្ថភាពរបស់គេដើម្បីអនុវត្តសកម្មភាពត្រួតពិនិត្យ ។
- គ- ត្រូវបញ្ចូលរបាយការណ៍នៅក្នុងសន្និបាតភាគី ស្តីពី លទ្ធផលសកម្មភាពនៃការត្រួតពិនិត្យលើមូលដ្ឋានតំបន់ និងពិភពលោកក្នុងចន្លោះពេលដែលបានកំណត់ដោយសន្និបាតភាគី ។

៣- ការវាយតំលៃដែលបានរៀបរាប់ក្នុងវាក្យខ័ណ្ឌ ១ នឹងត្រូវបានអនុវត្តលើមូលដ្ឋាននៃពត៌មានវិទ្យាសាស្ត្រ បរិស្ថាន បច្ចេកវិជ្ជា និងពត៌មានសេដ្ឋកិច្ចដែលអាចរកបាន ដោយរួមបញ្ចូល :

- ក- របាយការណ៍និងពត៌មានត្រួតពិនិត្យផ្សេងទៀត ដែលមានចែងក្នុងវាក្យខ័ណ្ឌ ២
- ខ- របាយការណ៍ជាតិដែលបានដាក់ជូនពិនិត្យ អនុលោមតាមមាត្រា ១៥
- គ- ពត៌មានពីការមិនប្រតិបត្តិតាមដែលមានចែងអនុលោមតាមទំរង់ការ ដែលបង្កើតឡើងក្រោមមាត្រា ១៧ ។

**មាត្រា ១៧ : ការមិនប្រតិបត្តិតាម**

សន្និបាតភាគី ឱ្យបានឆាប់តាមដែលអាចធ្វើបាន ត្រូវបង្កើតនិងអនុម័តលើទំរង់ការងារ និងយន្តការស្ថាប័នសំរាប់ធ្វើការកំណត់ការមិនប្រតិបត្តិតាមបទបញ្ញត្តិដែលចែងនៅក្នុងអនុសញ្ញានេះ និងសំរាប់កែលំអភាគីដែលបានរកឃើញថាពុំបានប្រតិបត្តិតាម ។

**<u>មាត្រា ១៨</u> : ដំណោះស្រាយវិវាទ**

១- ភាគីទាំងអស់ត្រូវដោះស្រាយនូវជម្លោះរវាងពួកគេ ដែលទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្ត អនុសញ្ញានេះតាមរយៈការចរចារ ឬមធ្យោបាយសន្តិវិធីដទៃទៀតតាមជំរើសរបស់គេ ។

២- នៅពេលធ្វើសច្ចានុម័ត ទទួលយក អនុម័ត ឬសុំចូលលើអនុសញ្ញា ឬនៅពេលណាមួយក្រោយនោះ ភាគីដែលមិនមែនជាអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ អាចប្រកាសជាលាយល័ក្ខអក្សរដាក់ជូនទៅការិយាល័យទទួលឯកសារ (depository) ថា ចំពោះទំនាស់ដែលពាក់ព័ន្ធការបកស្រាយ ឬការអនុវត្តនៃអនុសញ្ញានេះ គេទទួលស្គាល់នូវវិធីមួយ ឬទាំងពីរខាងក្រោមនៃការដោះស្រាយជម្លោះដោយខានពុំបានក្នុងការទាក់ទងជាមួយនឹងភាគីដែលបានទទួលការយល់ព្រមទៅនឹងកាតព្វកិច្ចដូចគ្នា :

ក- ការសំរេចនៃអាជ្ញាកណ្តាល ដោយអនុលោមទៅតាមទំរង់ការដែលនឹងត្រូវបានអនុម័តដោយសន្និបាតភាគីក្នុងឧបសម្ពន្ធមួយ តាមតែឆាប់ដែលអាចធ្វើបាន ។

ខ- ការដាក់បណ្តឹងជម្លោះទៅតុលាការអន្តរជាតិ ។

៣- ភាគីមួយដែលជាអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ អាចធ្វើសេចក្តីប្រកាសដោយមានប្រសិទ្ធិភាពដូចគ្នាក្នុងទំនាក់ទំនងទៅនឹងការសំរេចរបស់អាជ្ញាកណ្តាល ដោយអនុលោមទៅនឹងទំរង់ការចែងក្នុងវាក្យខ័ណ្ឌ ២ ( ក ) ។

៤- សេចក្តីប្រកាសដែលបានធ្វើឡើងតាមវាក្យខ័ណ្ឌ ២ ឬ ៣ នឹងនៅជាធរមានរហូតដល់ផុតពេលកំណត់ដោយអនុលោមទៅតាមល័ក្ខខ័ណ្ឌរបស់វា ឬរហូតដល់ ៣ ខែ ក្រោយពេលសេចក្តីជូនដំណឹងពីការដកពាក្យរបស់គេ ត្រូវបានដាក់ទៅការិយាល័យទទួលឯកសារ ។

៥- ការផុតកំណត់នៃសេចក្តីប្រកាសពីការដកហូតពាក្យបណ្តឹងមកវិញ ឬសេចក្តីប្រកាសជាថ្មីមួយ នឹងមិនមានឥទ្ធិពលលើទំរង់ការនៃការព្យួរទុកមុនពេលសាលាក្តី ឬតុលាការអន្តរជាតិវិនិច្ឆ័យ លុះត្រាណាតែភាគីជម្លោះយល់ព្រម ។

៦- ប្រសិនបើភាគីជម្លោះមិនបានយល់ព្រមដូចគ្នា ឬទំរង់ការណាមួយតាមវាក្យខ័ណ្ឌ ២ និងប្រសិនបើគេពុំមានលទ្ធភាពដោះស្រាយជម្លោះរបស់គេក្នុងរយៈពេល ១២ ខែ បន្ទាប់ពីការកំណត់សំគាល់ ដោយភាគីមួយទៅភាគីផ្សេងទៀតថាជម្លោះនេះកើតមានឡើងរវាងគេ ជម្លោះនោះត្រូវដាក់ជូនគណៈកម្មការដោះស្រាយតាមសំណូមពររបស់ភាគីជម្លោះ ។ គណៈកម្មការដោះស្រាយជម្លោះត្រូវផ្តល់របាយការណ៍មួយភ្ជាប់ជាមួយសំណូមពរ ។ ទំរង់ការផ្សេងបន្ថែមទៀតដែលទាក់ទងទៅនឹងគណៈកម្មការដោះស្រាយជម្លោះ ត្រូវរួមបញ្ចូលទៅក្នុងឧបសម្ពន្ធមួយដែលនឹងត្រូវអនុម័តដោយសន្និបាតភាគី មិនឱ្យយឺតជាងពេលប្រជុំលើកទី ២ ឡើយ ។

**មាត្រា ១៩ : សន្និបាតភាគី**

១- សន្និបាតភាគី ត្រូវបានរៀបចំតាមរយៈនេះ ។

២- កិច្ចប្រជុំលើកទី ១ នៃសន្និបាតភាគី នឹងត្រូវបានកោះប្រជុំដោយនាយកនិតិប្រតិបត្តិរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ មិនឱ្យលើសពី ១ ឆ្នាំ បន្ទាប់ពីអនុសញ្ញានេះត្រូវបានចូលជាធរមាន ។ បន្ទាប់មក ការប្រជុំជាធម្មតានៃសន្និបាតភាគីត្រូវរៀបចំឡើងក្នុងចន្លោះពេលដ៏ទៀងទាត់ ដែលនឹងត្រូវសំរេចដោយសន្និបាតភាគី ។

៣- ការប្រជុំវិសាមញ្ញសន្និបាតភាគី ត្រូវរៀបចំឡើងពេលណាមួយបើចាំជាការចាំបាច់ ដោយយោងតាមការកំណត់នៃសន្និបាតភាគី ឬដោយសំណូមពរជាលាយល័ក្ខអក្សរដោយភាគីណាមួយ និងបានផ្តល់សំលេងគាំទ្រ ១ ភាគ ៣ ពីភាគីទាំងអស់ ។

៤- ប្រជុំលើកទី ១ នៃសន្និបាតភាគីត្រូវអនុម័តនូវបទបញ្ជា ទំរង់ការនៃដំណើរការសន្និបាត និងអនុម័តគោលការណ៍ថវិកាសំរាប់សន្និបាត និងគណៈកម្មការសាខា ក៏ដូចជាការអនុម័តថវិកាសំរាប់ដំណើរការលេខាធិការដ្ឋាន ដោយការយល់ព្រមមតិភាគច្រើន ។

៥- សន្និបាតភាគី ជានិច្ចជាកាលត្រូវបន្តការពិនិត្យឡើងវិញ និងវាយតំលៃការប្រតិបត្តិអនុសញ្ញា នេះ ។ សន្និបាតភាគីត្រូវដំណើរការភារកិច្ចរបស់ខ្លួន ដែលកំណត់ដោយអនុសញ្ញាហួតដល់ទីបញ្ចប់ ហើយត្រូវ :

ក- យោងទៅលើសេចក្តីតំរូវការនៃវាក្យខ័ណ្ឌ ៦ បង្កើតគណៈកម្មការសាខាដោយគិតថាចាំបាច់សំរាប់ការអនុវត្តន៍អនុសញ្ញានេះ ។

ខ- សហការណ៍ជាមួយអង្គការមានសមត្ថកិច្ចអន្តរជាតិ អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ។

គ- ពិនិត្យឡើងវិញជាប្រចាំនូវរាល់ពត៌មានទាំងអស់ ដែលត្រូវបញ្ជូនទៅភាគីសមាជិក អនុលោមតាមមាត្រា ១៥ ដោយរួមបញ្ចូលនូវការពិចារណាពីប្រសិទ្ធភាពនៃវាក្យខ័ណ្ឌ ២ (ខ) ចំនុច (iii) នៃមាត្រា ៣ ។

ឃ- ពិចារណានិងទទួលរ៉ាប់រងនូវសកម្មភាពបន្ថែម ដែលអាចស្នើឡើងដើម្បីឈានទៅសំរេចបាននូវកម្មវត្ថុនៃអនុសញ្ញានេះ ។

៦- សន្និបាតភាគី នៃកិច្ចប្រជុំលើកទី ១ ត្រូវបង្កើតគណៈកម្មការមួយដែលមានឈ្មោះថា គណៈកម្មការពិនិត្យឡើងវិញនូវសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ក្នុងគោលបំណងដើម្បីចាត់តាំងមុខងាររបស់គណៈកម្មការនេះដែលកំណត់ដោយអនុសញ្ញារួមមាន :

ក- សមាជិករបស់គណៈកម្មការពិនិត្យឡើងវិញនៃសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ត្រូវបានចាត់តាំងដោយសន្និបាតភាគី ។ សមាជិកភាពរបស់គណៈកម្មការត្រូវមានអ្នកឯកទេសជំនាញក្នុងផ្នែកវាយតំលៃឬគ្រប់គ្រងសារធាតុគីមី ដែលបានចាត់តាំងដោយរដ្ឋាភិបាលជាភាគីសមាជិក ។ សមាជិករបស់គណៈកម្មការ នឹងត្រូវជ្រើសតាំងលើមូលដ្ឋានបែងចែកតាមភូមិសាស្ត្រស្មើភាព ។

ខ- សន្និបាតភាគីត្រូវធ្វើការអនុម័តពីល័ក្ខខ័ណ្ឌការងារ ស្ថាប័ន និងការប្រតិបត្តិរបស់គណៈកម្មការខាងលើ ។

គ- គណៈកម្មការត្រូវខិតខំធ្វើឱ្យមានអនុម័តនូវអនុសាសន៍របស់ខ្លួនដោយការយល់ព្រមភាគច្រើន ។ ប្រសិនបើការប្រឹងប្រែងឱ្យការយល់ព្រមភាគច្រើននោះត្រូវបានពិភាក្សាយ៉ាងល្អិតល្អន់ តែមិនទទួលបានការឯកភាព មធ្យោបាយក្រោយបំផុត គឺអនុសាសន៍ទាំងនោះនឹងត្រូវដាក់ឱ្យអនុម័តដោយការបោះឆ្នោតសំលេងពីរភាគបីនៃចំនួនសមាជិកវត្តមាន ។

៧- សន្និបាតភាគីនៃកិច្ចប្រជុំលើកទី ៣ ត្រូវវាយតំលៃនូវតំរូវការជាបន្ទាន់ សំរាប់ទំរង់ការដែលមានចែងក្នុងវាក្យខ័ណ្ឌ ២ (ខ) នៃមាត្រា ៣ រួមទាំងការគិតពិចារណាប្រសិទ្ធភាពរបស់វា ។

៨- អង្គការសហប្រជាជាតិ ភ្នាក់ងារជំនាញរបស់អង្គការនេះ និងភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ ក៏ដូចជារដ្ឋដែលមិនមែនជាភាគីរបស់អនុសញ្ញានេះ អាចចូលរួមជាអ្នកសង្កេតការនៅក្នុងការប្រជុំសន្និបាតភាគី ។ អង្គការ ឬភ្នាក់ងារណាមួយទោះជាជាតិ អន្តរជាតិ រដ្ឋាភិបាល ឬក្រៅរដ្ឋាភិបាលដែលមានគុណសម្បត្តិសមស្របទៅនឹងអនុសញ្ញា និងដែលបានជំរាបទៅលេខាធិការដ្ឋាននូវគោលបំណងខ្លួន ដើម្បីមានវត្តមាននៅឯកិច្ចប្រជុំសន្និបាតភាគីក្នុងនាមជាអ្នកសង្កេតការ អាចត្រូវបានអនុញ្ញាតលុះត្រាតែតិចជាងមួយភាគបីនៃភាគីមានវត្តមានមិនធ្វើការជំទាស់ ។ ការអនុញ្ញាតឱ្យចូលនិងការចូលរួមរបស់អ្នកសង្កេតការ ត្រូវគោរពតាមទំរង់ការដែលបានអនុម័តដោយសន្និបាតភាគី ។

## មាត្រា ២០ : លេខាធិការដ្ឋាន

១- លេខាធិការដ្ឋានមួយត្រូវបានបង្កើតតាមរយៈនេះ ។

២- តួនាទីភារកិច្ចរបស់លេខាធិការដ្ឋានត្រូវ :

ក- ធ្វើការរៀបចំការប្រជុំសន្និបាតភាគី និងគណៈកម្មាធិការសាខាអនុសញ្ញា និងផ្តល់សេវាដល់ការងារទាំងនោះតាមការស្នើសុំ ។

ខ- ធ្វើការសំរបសំរួលជួយដល់ភាគីទាំងអស់ ជាពិសេសភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីជាប្រទេសសេដ្ឋកិច្ចអន្តរកាល លើសំណើក្នុងការប្រតិបត្តិអនុសញ្ញានេះ ។

គ- ធានាការសំរបសំរួលជាមួយនឹងលេខាធិការដ្ឋាននៃគណៈកម្មាធិការអន្តរជាតិពាក់ព័ន្ធដទៃទៀត ។

ឃ- រៀបចំ និងចែកចាយដល់ភាគីនូវរបាយការណ៍ជាប្រចាំ ដោយផ្អែកលើមូលដ្ឋានពត៌មានដែលទទួលបានដោយអនុលោមតាមមាត្រា ១៥ និងពត៌មានផ្សេងទៀតដែលអាចរកបាន ។

ង- ចូលរួមក្នុងកិច្ចការរដ្ឋបាលនិងការរៀបចំកិច្ចសន្យា ដែលនឹងត្រូវតំរូវសំរាប់ប្រសិទ្ធិភាពនៃការផ្សព្វផ្សាយ នៅក្រោមគោលការណ៍ណែនាំទូទៅនៃសន្និបាតភាគី ។

ច- ចាត់ចែងតួនាទីផ្សេងទៀតរបស់លេខាធិការដ្ឋាន ដែលបានបញ្ជាក់ក្នុងអនុសញ្ញា និងមុខនាទីដ៏ទៃទៀត ដែលត្រូវបានកំណត់ដោយសន្និបាតភាគី ។

៣- តួនាទីជាលេខាធិការដ្ឋានសំរាប់អនុសញ្ញានេះ នឹងត្រូវបានដំណើរការដោយនាយកប្រតិបត្តិនៃកម្មវិធីបរិស្ថានសហប្រជាជាតិ ។ ការប្រគល់ភារកិច្ចជាលេខាធិការដ្ឋាននេះទៅឱ្យអង្គការអន្តរជាតិមួយ ឬច្រើនដ៏ទៃទៀត លុះត្រាតែមានការសំរេចចិត្តនៃសន្និបាតភាគីដោយការបោះឆ្នោតសំលេងបីភាគបួននៃភាគីដែលមានវត្តមាន ។

## មាត្រា ២១ : ការធ្វើវិសោធនកម្មអនុសញ្ញា

១- ការធ្វើវិសោធនកម្មលើអនុសញ្ញានេះ អាចនឹងត្រូវស្នើដោយភាគីណាមួយ ។

២- ការធ្វើវិសោធនកម្មនេះនឹងត្រូវបានអនុម័តក្នុងកិច្ចប្រជុំសន្និបាតភាគី ។ អត្ថបទស្តីពីការធ្វើវិសោធនកម្មដែលបានស្នើ នឹងត្រូវបានបញ្ជូនទៅភាគីទាំងអស់ដោយលេខាធិការដ្ឋានយ៉ាងហោចណាស់ ៦ ខែមុនពេលប្រជុំដើម្បីស្នើសុំការអនុម័ត ។ លេខាធិការដ្ឋានក៏នឹងត្រូវបញ្ជូនការស្នើធ្វើវិសោធនកម្មនេះ ទៅប្រទេសជាហត្ថលេខីនៃអនុសញ្ញានេះ និងទៅការិយាល័យទទួលឯកសារសំរាប់ជាពត៌មាន ។

៣- ភាគីទាំងអស់ត្រូវធ្វើការខិតខំប្រឹងប្រែងដើម្បីឈានដល់ការយល់ព្រម លើការស្នើធ្វើវិសោធនកម្មអនុសញ្ញានេះដោយការយល់ព្រមតិភាគច្រើន ។ ប្រសិនបើការប្រឹងប្រែងទាំងអស់ធ្វើឡើងដោយការពិភាក្សាយ៉ាងល្អិតល្អន់ ហើយនៅតែពុំបានឈានទៅដល់ការយល់ព្រម ការធ្វើវិសោធនកម្មនឹងត្រូវដោះស្រាយតាមមធ្យោបាយចុងក្រោយ ដែលនឹងត្រូវអនុម័តដោយការបោះឆ្នោតសំលេងបីភាគបួននៃភាគីដែលមានវត្តមាន ។

៤- សេចក្តីនៃវិសោធនកម្មដែលបានធ្វើ នឹងត្រូវបញ្ជូនដោយការិយាល័យទទួលឯកសារទៅរាល់គ្រប់ភាគីទាំងអស់ ដើម្បីផ្តល់សច្ចានុម័ត ទទួលយក ឬអនុម័ត ។

៥- ការផ្តល់សច្ចានុម័ត ទទួលយក ឬអនុម័តលើការធ្វើវិសោធនកម្ម ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរទៅការិយាល័យទទួលឯកសារ ។ ការធ្វើវិសោធនកម្មដែលបានអនុម័តដោយអនុលោមទៅតាមវាក្យខ័ណ្ឌ ៣ នឹងត្រូវដាក់ជាធរមានសំរាប់ភាគីដែលបានយល់ព្រមក្នុងរយៈពេល ៩០ ថ្ងៃ ក្រោយពីថ្ងៃដែលបានដាក់ឯកសារសុំធ្វើសច្ចានុម័ត ទទួលយក ឬអនុម័ត ដោយយ៉ាងហោចណាស់បីភាគបួននៃភាគី ។ បន្ទាប់មកការធ្វើវិសោធនកម្មនឹងត្រូវដាក់ជាធរមានសំរាប់ភាគីផ្សេងណាមួយក្នុងរយៈ ៩០ ថ្ងៃក្រោយថ្ងៃដែលភាគីនោះបានដាក់ឯកសារសុំធ្វើសច្ចានុម័ត ទទួលយក ឬអនុម័តនៃការធ្វើវិសោធនកម្មនោះ ។

**មាត្រា ២២ : ការអនុម័ត និងការធ្វើវិសោធនកម្មឧបសម្ព័ន្ធ**

១- ឧបសម្ព័ន្ធរបស់អនុសញ្ញានេះ គឺនឹងមានទំរង់ជាផ្នែករួមបញ្ចូល ដោយឡែកឡែងតែផ្នែកផ្សេងគ្នា ដែលរួមមាន : ជាឯកសារយោងរបស់អនុសញ្ញាដែលបង្កើតក្នុងពេលតែមួយ និងជាឯកសារយោងនៃឧបសម្ព័ន្ធដទៃទៀតដែលមានស្រាប់ ។

២- ឧបសម្ព័ន្ធបន្ថែម នឹងត្រូវបានភ្ជាប់ទៅនឹងបញ្ហាទំរង់ការ វិទ្យាសាស្ត្រ បច្ចេកទេស ឬរដ្ឋបាល ។

៣- ទំរង់ការខាងក្រោមនឹងអនុវត្តចំពោះការស្នើ ការអនុម័ត និងការចូលជាធរមាននៃឧបសម្ព័ន្ធបន្ថែម ចំពោះអនុសញ្ញានេះ :

ក- ឧបសម្ព័ន្ធបន្ថែមនឹងត្រូវបានស្នើ និងបានអនុម័ត ដោយយោងទៅតាមទំរង់ការដែលមានចែងក្នុង វាក្យខ័ណ្ឌ ១ វាក្យខ័ណ្ឌ ២ និងវាក្យខ័ណ្ឌ ៣ នៃមាត្រា ២១ ។

ខ- ភាគីណាមួយដែលពុំមានលទ្ធភាពដើម្បីយល់ព្រមតាមឧបសម្ព័ន្ធបន្ថែម ត្រូវជូនដំណឹងទៅការិយាល័យទទួលឯកសារជាលាយល័ក្ខអក្សរក្នុងរយៈពេល ១ ឆ្នាំគិតចាប់ពីថ្ងៃជូនដំណឹងដោយការិយាល័យទទួលឯកសារពីការអនុម័តនៃឧបសម្ព័ន្ធបន្ថែម ។ ការិយាល័យទទួលឯកសារដោយមិនពន្យាពេល ត្រូវជូនដំណឹងទៅរាល់ភាគីពីការទទួលនូវសេចក្តីជូនដំណឹងនោះ។ ភាគីមួយអាចដកមកវិញគ្រប់ពេលនូវសេចក្តីជូនដំណឹងពីមុននៃការមិនយល់ព្រមចំពោះឧបសម្ព័ន្ធបន្ថែម ហើយឧបសម្ព័ន្ធនោះនឹងត្រូវបានចូលជាធរមានសំរាប់ភាគីនោះដែលស្ថិតនៅក្រោមល័ក្ខខ័ណ្ឌ ដែលមានចែង ក្នុងកថាខ័ណ្ឌ គ ។

គ- ក្រោយរយៈពេល ១ ឆ្នាំ គិតពីថ្ងៃនៃការផ្តល់ពត៌មានដោយការិយាល័យទទួលឯកសារ ពីការអនុម័តនូវឧបសម្ព័ន្ធបន្ថែម ឧបសម្ព័ន្ធនឹងចូលជាធរមានសំរាប់រាល់ភាគីទាំងអស់ ដែលមិនបានដាក់ការជូនដំណឹងជាមុន ដោយអនុលោមទៅតាមបទបញ្ញត្តិដែលចែងក្នុងកថាខ័ណ្ឌ ខ ។

៤- ការស្នើសុំ ការអនុម័ត និងការចូលជាធរមាននូវការធ្វើវិសោធនកម្មឧបសម្ព័ន្ធ ( ក ) ឧបសម្ព័ន្ធ ( ខ ) ឬ ឧបសម្ព័ន្ធ ( គ) ត្រូវស្ថិតនៅក្រោមទំរង់ការដូចគ្នានឹងការស្នើសុំ ការអនុម័ត និងការចូលជាធរមាននូវឧបសម្ព័ន្ធបន្ថែមនៃអនុសញ្ញានេះ លើកលែងចំពោះការធ្វើវិសោធនកម្មឧបសម្ព័ន្ធ ( ក ) ឧបសម្ព័ន្ធ ( ខ ) ឬ ឧបសម្ព័ន្ធ ( គ) នឹងមិនចូលជាធរមានចំពោះភាគីណាមួយដែលបានធ្វើការប្រកាស ចំពោះការធ្វើវិសោធនកម្មនៃឧបសម្ព័ន្ធនោះ អនុលោមទៅតាមវាក្យខ័ណ្ឌ ៤ នៃមាត្រា ២៥ ហើយដែលនៅក្នុងករណីនោះ ការធ្វើវិសោធនកម្មនឹងត្រូវចូលជាធរមានសំរាប់ភាគីនោះក្នុងរយៈពេល ៩០ ថ្ងៃ ក្រោយពេលផ្ញើរឯកសារទៅការិយាល័យទទួលឯកសារ នូវបែបបទរបស់ខ្លួនសំរាប់ការផ្តល់សច្ចានុម័ត ការទទួលយក ការអនុម័ត ឬការសុំចូលចំពោះការធ្វើវិសោធនកម្មនោះ ។

៥- ទំរង់ការខាងក្រោមត្រូវអនុវត្តន៍ចំពោះការស្នើ ការអនុម័ត និងការចូលជាធរមាននូវការធ្វើវិសោធនកម្ម ចំពោះឧបសម្ព័ន្ធ ( ឃ ) ឧបសម្ព័ន្ធ ( ង ) ឬឧបសម្ព័ន្ធ ( ច )

ក- ការធ្វើវិសោធនកម្ម នឹងត្រូវបានស្នើយោងទៅតាមទំរង់ការក្នុងវាក្យខ័ណ្ឌ ១ និងវាក្យខ័ណ្ឌ ២ នៃមាត្រា ២១ ។

ខ- ភាគីត្រូវធ្វើការសំរេចចិត្តលើការធ្វើវិសោធនកម្មចំពោះឧបសម្ព័ន្ធ ( ឃ ) ឧបសម្ព័ន្ធ ( ង ) ឬ ឧបសម្ព័ន្ធ ( ច ) ដោយការឯកភាពមតិភាគច្រើន ។

គ- ការសំរេចចិត្តមួយដើម្បីធ្វើវិសោធនកម្មឧបសម្ព័ន្ធ ( ឃ ) ឧបសម្ព័ន្ធ ( ង ) ឬ ឧបសម្ព័ន្ធ ( ច ) នឹងត្រូវធ្វើការជូនដំណឹងភ្លាមទៅភាគីដោយការិយាល័យទទួលឯកសារ ។ ការធ្វើវិសោធនកម្មនឹងត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការសំរាប់ភាគីទាំងអស់នៅថ្ងៃ ដែលបានកំណត់ដោយការសំរេចចិត្ត ។

៦- ប្រសិនបើឧបសម្ព័ន្ធបន្ថែម ឬការធ្វើវិសោធនកម្មចំពោះឧបសម្ព័ន្ធមួយ ត្រូវបានទាក់ទងនឹងការធ្វើវិសោធនកម្មអនុសញ្ញានេះ ឧបសម្ព័ន្ធបន្ថែម ឬការធ្វើវិសោធនកម្មនោះ នឹងមិនត្រូវបានចូលជាធរមានរហូតដល់ពេលមួយដែលការធ្វើវិសោធនកម្មអនុនៃសញ្ញានេះបានចូលជាធរមាន ។

## <u>មាត្រា ២៣</u> : សិទ្ធិបោះឆ្នោត

១- ភាគីនិមួយៗនៃអនុសញ្ញានេះនឹងត្រូវបោះឆ្នោត ១ សំលេង លើកលែងអ្វីដែលបានចែងក្នុងវាក្យខ័ណ្ឌ ២ ខាងក្រោម ។

២- ផ្អែកលើសមត្ថកិច្ចរបស់ខ្លួន អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ នឹងត្រូវប្រើសិទ្ធិរបស់គេដើម្បីបោះឆ្នោតដោយចំនួនសំលេងស្មើនឹងចំនួននៃសមាជិករដ្ឋរបស់ខ្លួនដែលជាភាគីនៃអនុសញ្ញានេះ ។ អង្គការនេះនឹងមិនត្រូវប្រើសិទ្ធិរបស់គេដើម្បីបោះឆ្នោត ប្រសិនបើរដ្ឋជាសមាជិករបស់គេបានប្រើសិទ្ធិរបស់ខ្លួនដើម្បីធ្វើការបោះឆ្នោត និងផ្ទុយមកវិញ ។

## <u>មាត្រា ២៤</u> : ការចុះហត្ថលេខា

អនុសញ្ញានេះនឹងត្រូវបើកដោយសេរី ដើម្បីចុះហត្ថលេខានៅទីក្រុង **ស្តុកខូម** ( Stockholm ) សំរាប់រដ្ឋទាំងអស់ និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ នៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០០១ និងនៅការិយាល័យអង្គការសហប្រជាជាតិ នាទីក្រុងញូវយ៉ក ពីថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០១ ដល់ថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០២ ។

## <u>មាត្រា ២៥</u> : ការឱ្យសច្ចានុម័ត ការទទួលយក ការអនុម័ត ឬការសុំចូល

១- អនុសញ្ញានេះនឹងត្រូវដាក់ឱ្យធ្វើសច្ចានុម័ត ទទួលយក ឬអនុម័តដោយរដ្ឋ និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ។ វានឹងបើកទូលាយសំរាប់ការសុំចូលដោយរដ្ឋ និងដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់

ចាប់ពីថ្ងៃដែលអនុសញ្ញានេះបានបិទលែងឱ្យមានការចុះហត្ថលេខា ។ បរិធានបែបបទសំរាប់ធ្វើសច្ចានុម័ត ទទួលយក ការអនុម័ត ឬការសុំចូលនឹងត្រូវរក្សាទុកនៅការិយាល័យទទួលឯកសារ ។

២- អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ណាមួយ ដែលក្លាយទៅភាគីរបស់អនុសញ្ញានេះដោយពុំមានសមាជិកនៃរដ្ឋណាមួយរបស់ខ្លួនជាភាគីនៃអនុសញ្ញានេះ នឹងត្រូវទទួលអនុវត្តនូវកាតព្វកិច្ចទាំងអស់របស់អនុសញ្ញានេះ ។ ក្នុងករណីដែលសមាជិករដ្ឋមួយ ឬច្រើននៃអង្គការនេះជាភាគីនៃអនុសញ្ញានេះ អង្គការនេះ និងសមាជិករដ្ឋរបស់ខ្លួននឹងត្រូវសំរេចលើការទទួលខុសត្រូវរៀងៗខ្លួនរបស់គេ ដើម្បីអនុវត្តន៍ភារកិច្ចរបស់គេក្រោមអនុសញ្ញានេះ ។ ក្នុងករណីនេះ អង្គការនិងរដ្ឋជាសមាជិករបស់គេ នឹងមិនត្រូវបានឱ្យអំណាចប្រើសិទ្ធិក្រោមអនុសញ្ញាបច្ចុប្បន្ននេះ ។

៣- នៅក្នុងបរិធានរបស់គេសំរាប់ការឱ្យសច្ចានុម័ត ការទទួលយក ការអនុម័ត ឬការសុំចូលអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ត្រូវធ្វើការប្រកាសនូវវិសាលភាពពីសមត្ថកិច្ចរបស់គេ ចំពោះអ្វីដែលបានគ្រប់គ្រងដោយអនុសញ្ញានេះ ។ អង្គការបែបនេះ ត្រូវជូនដំណឹងផងដែរទៅការិយាល័យទទួលឯកសារដែលមានភារៈជូនដំណឹងទៅភាគីផ្សេងៗ នូវអ្វីដែលទាក់ទងទៅនឹងការប្រែប្រួលនូវទំហំសមត្ថកិច្ចរបស់គេ ។

៤- នៅក្នុងបរិធានបែបបទរបស់គេសំរាប់ការឱ្យសច្ចានុម័ត ការទទួលយក ការអនុម័ត ឬការសុំចូលភាគីនិមួយៗ អាចធ្វើសេចក្តីជូនដំណឹងថា ចំពោះអង្គការខ្លួនការធ្វើវិសោធនកម្មចំពោះតារាងឧបសម្ព័ន្ធ (ក) ឧបសម្ព័ន្ធ (ខ) ឬឧបសម្ព័ន្ធ (គ) នឹងចូលជាធរមាន លើការដាក់ជូនបរិធានឯកសារធ្វើសច្ចានុម័ត ការទទួលយក ការអនុម័ត ឬការសុំចូល ដោយយោងទៅលើបរិធាននោះ ។

## មាត្រា ២៦ : ការចូលជាធរមាន

១- អនុសញ្ញានេះនឹងចូលជាធរមានក្នុងរយៈពេល ៩០ ថ្ងៃក្រោយកាលបរិច្ឆេទនៃការដាក់ឯកសារធ្វើសច្ចានុម័ត ទទួលយក អនុម័ត ឬសុំចូលលើកទី ៥០ ។

២- សំរាប់ប្រទេសនិមួយៗ ឬអង្គការសេដ្ឋកិច្ចរួមក្នុងតំបន់ដែលធ្វើសច្ចានុម័ត ទទួលយក ឬអនុម័តអនុសញ្ញានេះ ឬសុំចូលជាសមាជិកក្រោយពីការដាក់ឯកសារទី ៥០ នៃការធ្វើសច្ចានុម័ត ការទទួលយក ការអនុម័ត ឬការសុំចូលអនុសញ្ញានេះ នឹងចូលជាធរមានក្នុងរយៈពេល ៩០ ថ្ងៃក្រោយកាលបរិច្ឆេទនៃការដាក់ឯកសាររបស់រដ្ឋ ឬអង្គការ សមាហរណកម្មសេដ្ឋកិច្ចនូវបែបបទរបស់ខ្លួនសំរាប់ធ្វើសច្ចានុម័ត ទទួលយក អនុម័ត ឬការសុំចូល ។

៣- សំរាប់គោលបំណងនៅក្នុងវាក្យខ័ណ្ឌ ១ និង ២ បរិធានឬឯកសារដែលបានដាក់សុំដោយអង្គការសេដ្ឋកិច្ចរួមក្នុងតំបន់ នឹងមិនត្រូវបានរាប់បញ្ចូលបន្ថែមទេ ចំពោះឯកសារដែលត្រូវបានដាក់បញ្ចូលដោយប្រទេសជាសមាជិករបស់អង្គការនេះ ។

**មាត្រា ២៧ : ការបំរុងទុក**

មិនមានការបំរុងទុកណាមួយដែលត្រូវបានធ្វើឡើងចំពោះអនុសញ្ញានេះទេ ។

**មាត្រា ២៨ : ការដកចេញ**

១- នៅគ្រប់ពេល ក្រោយរយៈពេល ៣ ឆ្នាំពីថ្ងៃដែលអនុសញ្ញានេះបានចូលជាធរមានសំរាប់ភាគី ភាគីនោះអាចដកខ្លួនចេញពីអនុសញ្ញា ដោយធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរទៅការិយាល័យទទួលឯកសារ ។

២- ការដកចេញនឹងចូលជាធរមានលើការកំណត់រយៈពេល ១ ឆ្នាំ គិតពីកាលបរិច្ឆេទនៃការទទួលដោយការិយាល័យទទួលឯកសារនូវឯកសារសុំចេញ ឬលើកាលបរិច្ឆេទចុងក្រោយ ដូចបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងនៃការដកចេញ ។

**មាត្រា ២៩ : ការិយាល័យទទួលឯកសារ**

អគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ នឹងបំពេញភារកិច្ចជាការិយាល័យទទួលឯកសាររបស់អនុសញ្ញានេះ ។

**មាត្រា ៣០ : អត្ថបទដើម**

ឯកសារច្បាប់ដើមនៃអនុសញ្ញានេះមានជាអក្សរ **អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី** និង **អេស្ប៉ាញ** ហើយដែលមានតំលៃតាមច្បាប់ដើមដូចគ្នា នឹងត្រូវតំកល់ទុកនៅអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ ។

សាក្សីដែលបានចុះហត្ថលេខា គឺមានសិទ្ធពេញលេញចំពោះការចូលជាធរមាននោះ ហើយបានចុះហត្ថលេខាលើអនុសញ្ញានេះ ។

**បានធ្វើនៅក្រុងស្តុកខូម នៅថ្ងៃទី ២២ ខែឧសភា ២០០១**

សេចក្តីបកប្រែមិនផ្លូវការ

# ឧបសម្ព័ន្ធ ក

## ការលុបបំបាត់

### ផ្នែកទី ១

| សារធាតុគីមី | សកម្មភាព | ករណីលើកលែងពិសេស |
|---|---|---|
| Aldrin*<br>CAS No: 309 - 00-2 | ការផលិត | - មិន |
| | ប្រើប្រាស់ | - ថ្នាំសំលាប់សត្វល្អិតប៉ាសិតក្នុងស្រុក |
| Chlordane*<br>CAS No: 57- 74 - 9 | ការផលិត | - ត្រូវបានអនុញ្ញាតដល់សមាជិកដែលបានចុះក្នុងបញ្ជី |
| | ការប្រើប្រាស់ | - ថ្នាំសំលាប់សត្វល្អិតប៉ាសិតក្នុងស្រុក<br>- ថ្នាំសំលាប់សត្វល្អិត<br>- ថ្នាំសំលាប់សត្វកណ្តៀរ<br>- ថ្នាំសំលាប់សត្វកណ្តៀរក្នុងការងារសំណង់ និងទំនប់ទឹក<br>- ថ្នាំសំលាប់សត្វកណ្តៀរសំរាប់សំណង់ផ្លូវ<br>- សារធាតុស្អិតសំរាប់ប្រើលើក្តារបន្ទះ |
| Dieldrin*<br>CAS No: 60-57-1 | ការផលិត | - មិន |
| | ការប្រើប្រាស់ | - សំរាប់ប្រតិបត្តិខាងផ្នែកកសិកម្ម |
| Endrin*<br>CAS No: 72-20-8 | ការផលិត | - មិន |
| | ការប្រើប្រាស់ | - មិន |
| Heptachlor*<br>CAS No : 76-44-8 | ការផលិត | - មិន |
| | ការប្រើប្រាស់ | - ថ្នាំសំលាប់សត្វកណ្តៀរ<br>- ថ្នាំសំលាប់សត្វកណ្តៀរលើគ្រឿងសំណង់ផ្ទះ<br>- ថ្នាំសំលាប់សត្វកណ្តៀរក្នុងដី<br>- ការសំអាតឈើ<br>- ការប្រើប្រាស់សំរាប់ប្រអប់ខ្សែភ្លើងក្រោមដី |
| Hexachlorobenzene<br>CAS No: 118-74-1 | ការផលិត | - ត្រូវបានអនុញ្ញាតដល់សមាជិកដែលបានចុះក្នុងបញ្ជី |
| | ការប្រើប្រាស់ | - ជាសារធាតុគីមីអន្តរការី<br>- ជាសារធាតុរំលាយក្នុងថ្នាំសំលាប់សត្វល្អិត<br>- ជាសារធាតុគីមីអន្តរការីមានការកំរិតប្រើនៅទីតាំងបិទជិត |

| | | |
|---|---|---|
| Mirex*<br>CAS No: 2385-85-5 | ការផលិត | - ត្រូវបានអនុញ្ញាតដល់សមាជិកដែលបានចុះក្នុងបញ្ជី |
| | ការប្រើប្រាស់ | - ថ្នាំសំលាប់កណ្ដៀរ |
| Toxaphene*<br>CAS No: 8001-35-2 | ការផលិត | - មិន |
| | ការប្រើប្រាស់ | - មិន |
| Polychlorinated biphenyls* ( PCB ) | ការផលិត | - មិន |
| | ការប្រើប្រាស់ | - ឧបករណ៍កំពុងប្រើប្រាស់ ដោយយោងទៅតាមបទបញ្ញត្តិ ដែលមានចែងក្នុងផ្នែកទី 2 នៃឧបសម្ពន្ធនេះ |

## កត់សំគាល់

( i ) ក្រៅពីអ្វីដែលមានចែងនៅក្នុងអនុសញ្ញានេះ សារធាតុគីមីមួយចំនួនដែលកើតឡើងជាសារធាតុបំពុលកំរនិងមិនបានការនៅក្នុងផលិតផលនិងឧបករណ៍ប្រើប្រាស់ នឹងមិនត្រូវបានយកមកពិចារណារដើម្បីចុះក្នុងតារាងឧបសម្ពន្ធនេះទេ ។

( ii ) ការកត់សំគាល់នេះ នឹងមិនត្រូវបានពិចារណាចំពោះករណីលើកលែងពិសេសនៃការផលិត និងការប្រើប្រាស់សំរាប់គោលបំណងនៃវាក្យខ័ណ្ឌ ២ មាត្រា ៣ ទេ។ សារធាតុគីមីមួយចំនួនដែលកើតឡើងជាធាតុផ្សំនៃឧបករណ៍ប្រើប្រាស់ដែលបានផលិត ឬបានប្រើប្រាស់ពីមុនមក ឬចាប់ពីថ្ងៃចូលជាធរមាននៃកាតព្វកិច្ចដែលទាក់ទងទៅនឹងសារធាតុគីមីនោះ នឹងមិនត្រូវបានយកមកពិចារណាជាការចុះបញ្ជីក្នុងតារាងឧបសម្ពន្ធនេះទេ ហើយដែលបានកំណត់ថា ភាគីបានជូនដំណឹងទៅលេខាធិការដ្ឋានថា ប្រភេទនៃវត្ថុនោះគឺកំពុងបន្តប្រើប្រាស់ដោយភាគីជាសមាជិកនោះ ។ លេខាធិការដ្ឋានត្រូវធ្វើសេចក្តីជូនដំណឹងជាសាធារណៈតាមដែលអាច ។

( iii ) ការកត់សំគាល់នេះ ដែលមិនសំដៅទៅលើសារធាតុគីមីដែលមានសញ្ញា (*) បន្ទាប់ពីឈ្មោះវាក្នុងតារាងគីមីនៅផ្នែកទី ១ នៃតារាងឧបសម្ពន្ធនេះ នឹងមិនត្រូវបានលើកយកមកពិចារណាចំពោះករណីលើកលែងពិសេសនៃការផលិត និងការប្រើប្រាស់សំរាប់គោលបំណងនៃវាក្យខ័ណ្ឌ ២ មាត្រា ៣ ទេ។

ដោយការចាត់ថា វាមិនមែនជាសារធាតុគីមីសំខាន់ៗ ដែលត្រូវបានគេរំពឹងថាចូលក្នុងខ្លួនមនុស្ស និងបរិស្ថាន ក្នុងពេលផលិតនិងប្រើប្រាស់ជាសារធាតុគីមីអន្តរការី ដែលមានការកំណត់ក្នុងការប្រើប្រាស់វានៅទីតាំងបិទជិត (closed-system site-limited intermadiate) ភាគីជាសមាជិកដោយផ្អែកលើការជូនដំណឹងជាមុនទៅលេខាធិការដ្ឋាន អាចអនុញ្ញាតឱ្យផលិតនិងការប្រើប្រាស់សារធាតុគីមីមួយចំនួនដែលបានចុះក្នុងតារាងឧបសម្ពន្ធនេះ ជាសារធាតុគីមីអន្តរការីដែលមានការកំរិតក្នុងការប្រើប្រាស់នៅទីតាំងបិទជិត (closed-system site-limited intermadiate) ដោយលក្ខណៈគីមីរបស់វាត្រូវបានបំលែងក្នុងការបង្កើតជាសារធាតុគីមីដទៃ ដែលគោរពតាមល័ក្ខខ័ណ្ឌវិនិច្ឆ័យក្នុងវាក្យខ័ណ្ឌ ១ ឧបសម្ពន្ធ (ឃ) ហើយដែលសារធាតុគីមីកើតថ្មីនោះមិនបានបង្ហាញលក្ខណៈគីមីជាសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ។

សេចក្តីជូនដំណឹងជាមុនទៅលេខាធិការដ្ឋាន ត្រូវបញ្ចូលនូវពត៌មាន ស្តីពី បរិមាណសរុបនៃការផលិត និងការប្រើប្រាស់នូវសារធាតុគីមីនោះ ឬធ្វើការប៉ាន់ប្រមាណឱ្យបានសមស្របនូវពត៌មាននេះនិងពត៌មានដែលទាក់ទងទៅនឹងប្រភេទនៃដំណើរការដែលមានការកើតក្នុងការប្រើប្រាស់នៅទីតាំងបិទជិត (closed-system site-limited) ដោយរួមបញ្ចូលនូវបរិមាណសារធាតុបំពុលដែលមិនប្រែធាតុ និងការបំពុលដែលកើតដោយឯងៗពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ (ឧបករណ៍ ឬវត្ថុដែលកើតមាននៅក្នុងផលិតផលតំបូង)។ ការអនុវត្តទំរង់ការនេះ ត្រូវបានលើកលែងចំពោះអ្វីដែលមានចែងនៅក្នុងឧបសម្ពន្ធនេះ ។

លេខាធិការដ្ឋាន ត្រូវផ្ញើរសេចក្តីជូនដំណឹងជាមុននោះទៅសន្និបាតភាគី និងធ្វើរជាសាធារណៈ ។ ការផលិត និងការប្រើប្រាស់បែបខាងលើនេះ នឹងមិនត្រូវចាត់ទុកថាជាការផលិតនិងប្រើប្រាស់ក្នុងករណីពិសេសទេ។ ការផលិតនិងការប្រើប្រាស់បែបនេះ នឹងត្រូវបញ្ឈប់ក្រោយរយៈពេល ១០ ឆ្នាំបន្ទាប់ លុះត្រាតែភាគីដែលពាក់ព័ន្ធដាក់សេចក្តីជូនដំណឹងថ្មីទៅលេខាធិការដ្ឋាន ក្នុងករណីនេះ រយៈពេលនឹងត្រូវបានពន្យារពេលបន្ថែម ១០ ឆ្នាំទៀត លុះត្រាតែសន្និបាតភាគីធ្វើការសំរេច ក្រោយពីការពិនិត្យឡើងវិញនូវការផលិតនិងការប្រើប្រាស់នោះ ។ និតិវិធីនៃការជូនដំណឹងអាចត្រូវបានធ្វើសារជាថ្មី ។

(iv) រាល់ករណីលើកលែងពិសេសនៅក្នុងតារាងឧបសម្ពន្ធនេះ អាចត្រូវបានអនុវត្តន៍ដោយភាគីជាសមាជិក ដែលបានចុះបញ្ជីការលើកលែងតាមការស្នើរបស់គេ ដោយអនុលោមតាមមាត្រា ៤ ដោយករណីលើកលែងលើការប្រើប្រាស់សារធាតុ Polychlorinated Biphenyls ក្នុងឧបករណ៍កំពុងប្រើប្រាស់ ដោយអនុលោមតាមបទបញ្ញត្តិផ្នែកទី ២ នៃតារាងឧបសម្ពន្ធនេះ ដែលត្រូវបានអនុវត្តន៍ដោយភាគីជាសមាជិក ។

## ផ្នែកទី ២
## Polychlorinated Biphenyls

ភាគីនិមួយៗ ត្រូវៈ

ក- ទាក់ទងទៅនឹងការលុបបំបាត់នៃការប្រើប្រាស់សារធាតុ Polychlorinated Biphenils (PCBs) នៅក្នុងគ្រឿងបរិក្ខារ ដូចជា ត្រង់ស្វូ (transformators) ឬ កាប៉ាស៊ីទ័រ (capacitors) ឬឧបករណ៍មានផ្ទុកសារធាតុរាវប្រភេទនេះ ត្រឹមឆ្នាំ ២០២៥ ដែលត្រូវពិនិត្យឡើងវិញដោយសន្និបាតភាគី ចាត់វិធានការដោយអនុលោមនូវចំនុចអាទិភាពខាងក្រោម :

(i) ធ្វើការខិតខំដើម្បីកំណត់ ដាក់ស្លាកសញ្ញា និងយកចេញពីឧបករណ៍ប្រើប្រាស់ដែលមានផ្ទុក PCBs ច្រើនជាង ១០ % និងដែលមានចំណុះច្រើនជាង ៥ លីត្រ ។

(ii) ធ្វើការខិតខំដើម្បីកំណត់ ដាក់ស្លាកសញ្ញា និងយកចេញពីឧបករណ៍ប្រើប្រាស់ដែលមានផ្ទុក PCBs ច្រើនជាង ០.០៥ % និងដែលមានចំណុះច្រើនជាង ៥ លីត្រ ។

(iii) ធ្វើការជំរុញដើម្បីកំណត់ និងយកចេញពីឧបករណ៍ប្រើប្រាស់ដែលមានផ្ទុក PCBs ច្រើនជាង ០.០០៥ % និងដែលមានចំណុះច្រើនជាង ០.០៥ លីត្រ ។

ខ- ស្របទៅតាមចំនុចអាទិភាពក្នុងកថាខ័ណ្ឌ ក ខាងលើ បង្កើននូវវិធានការខាងក្រោមដើម្បីកាត់បន្ថយការទទួលរង និងភាពគ្រោះថ្នាក់ ដើម្បីត្រួតពិនិត្យការប្រើប្រាស់ PCBs :

(i) ប្រើប្រាស់តែគ្រឿងសំភារៈដែលមិនខូចនិងមិនលេចជ្រាប និងនៅក្នុងតំបន់ដែលភាពគ្រោះថ្នាក់ពីការសាយភាយទៅក្នុងបរិស្ថាន អាចត្រូវបានកាត់បន្ថយនិងស្តារឡើងវិញយ៉ាងរហ័ស ។

(ii) មិនអនុញ្ញាតឱ្យប្រើប្រាស់គ្រឿងបរិក្ខារទាំងនោះនៅទីតាំងជាប់កន្លែងផលិត ឬកែច្នៃម្ហូបអាហារ ឬផ្គត់ផ្គង់ ។

(iii) នៅពេលមានការប្រើប្រាស់នៅទីកន្លែងដែលមានមនុស្សរស់នៅច្រើន ដូចជាសាលារៀន និងមន្ទីរពេទ្យ វិធានការសមស្រប គឺត្រូវការពារការខូចនូវបណ្តាញអគ្គិសនីដែលអាចបង្កឱ្យមានជាអគ្គិភ័យ និងត្រូវធ្វើការត្រួតពិនិត្យជាប្រចាំនូវឧបករណ៍ដែលអាចនឹងលេចជ្រាប ។

គ- ថ្វីបើមានចែងនៅក្នុងវាក្យខ័ណ្ឌ ២ នៃមាត្រា ៣ ធានាថា គ្រឿងបរិក្ខារដែលមានផ្ទុក PCBs ដូចដែលបានរៀបរាប់នៅក្នុងកថាខ័ណ្ឌ ក ខាងលើ នឹងមិនត្រូវអនុញ្ញាតនាំចេញ ឬនាំចូល លើកលែងតែសំរាប់គោលបំណងនៃការគ្រប់គ្រងសំណល់ប្រកបដោយសុវត្ថិភាពបរិស្ថាន ។

ឃ- លើកលែងតែសំរាប់ដំណើរការថែទាំ និងដំណើរការសេវាកម្ម នឹងមិនត្រូវអនុញ្ញាតឱ្យមានការកែច្នៃសំរាប់គោលបំណងនៃការប្រើប្រាស់ឡើងវិញនូវគ្រឿងបរិក្ខារដែលមានផ្ទុកសារធាតុរាវ ដែលក្នុងនោះកំហាប់ PCBs ច្រើនជាង ០.០០៥ % ។

ង- ធ្វើការប្រឹងប្រែងក្នុងការរៀបចំផែនការ ដើម្បីឈានទៅដល់ការគ្រប់គ្រងសំណល់ប្រកបដោយសុវត្ថិភាពបរិស្ថាននូវសារធាតុរាវដែលមានផ្ទុក PCBs និងគ្រឿងបរិក្ខារដែលមានផ្ទុក PCBs ដែលមានកំហាប់ PCBs ច្រើនជាង ០.០០៥ % ដោយយោងទៅតាមវាក្យខ័ណ្ឌ ១ មាត្រា ៦ ឱ្យបានឆាប់តាមលទ្ធភាពដែលអាច ប៉ុន្តែមិនលើសពីឆ្នាំ ២០២៨ ដែលនឹងត្រូវធ្វើការពិនិត្យឡើងវិញដោយសន្និបាតភាគី ។

ច- ក្រៅពីការចែងនៅក្នុងកំណត់សំគាល់ (ii) ផ្នែកទី ១ នៃឧបសម្ព័ន្ធនេះ ខិតខំប្រឹងប្រែងដើម្បីកំណត់នូវឧបករណ៍ដទៃទៀតដែលមានផ្ទុក PCBs ច្រើនជាង ០.០០៥ % ឧទាហរណ៍ ដូចជា : ស្រោមខ្សែភ្លើង ឧបករណ៍ដែលមានលាបថ្នាំពណ៌ ដែលនឹងត្រូវគ្រប់គ្រងដោយអនុលោមតាមវាក្យខ័ណ្ឌ ១ នៃមាត្រា ៦ ។

ឆ- ផ្តល់របាយការណ៍ជារៀងរាល់ ៥ ឆ្នាំម្តង ពីការវិវត្តន៍ក្នុងការលុបបំបាត់សារធាតុ PCBs និងដាក់ជូនក្នុងសន្និបាតភាគី យោងទៅតាមមាត្រា ១៥ ។

សេចក្តីបកប្រែមិនផ្លូវការ

ជ- របាយការណ៍ដែលមានចែងក្នុងកថាខ័ណ្ឌ ឆ ខាងលើ នឹងត្រូវបានពិចារណាដោយសន្និបាតភាគីក្នុងការពិនិត្យឡើងវិញពីបញ្ហាដែលទាក់ទងជាមួយសារធាតុ PCBs។ សន្និបាតភាគី ត្រូវតែពិនិត្យនូវការវិវត្តន៍ទៅមុខក្នុងការលុបបំបាត់ PCBs ក្នុងចន្លោះពេល ៥ ឆ្នាំ ឬក្នុងរយៈពេលដ៏ទៃទៀត ដែលយោងលើរបាយការណ៍ដាក់ជូន ។

## ឧបសម្ព័ន្ធ ខ

## ការដាក់កំរិត

## ផ្នែកទី ១

| សារធាតុគីមី | សកម្មភាព | គោលបំណងដែលអាចទទួលយកបាន ឬករណីលើកលែងពិសេស |
|---|---|---|
| DDT ( 1,1,1- trichloro-2-2- bis ( 4- chlorophenyl ) ethane ) CAS No 50-29-3 | ការផលិត | គោលបំណងដែលអាចទទួលយកបាន :<br>- ការប្រើប្រាស់សំរាប់ត្រួតពិនិត្យសត្វល្អិតបង្កជំងឺ ដោយអនុលោមតាមផ្នែកទី ២ ឧបសម្ព័ន្ធនេះ<br>ករណីលើកលែងពិសេស :<br>- ជាអន្តរការីក្នុងការផលិតឌូរ៉ dicofol<br>- ជាអន្តរការី |
| | ការប្រើប្រាស់ | គោលបំណងដែលអាចទទួលយកបាន :<br>- ការប្រើប្រាស់សំរាប់ត្រួតពិនិត្យសត្វល្អិតបង្កជំងឺ ដោយអនុលោមតាមផ្នែកទី ២ ឧបសម្ព័ន្ធនេះ<br>ករណីលើកលែងពិសេស :<br>- ការផលិតឌូរ៉ dicofol<br>- ជាអន្តរការី |

**កត់សំគាល់ :**

( i ) ក្រៅពីអ្វីដែលមានចែងនៅក្នុងអនុសញ្ញានេះ សារធាតុគីមីមួយចំនួនដែលកើតឡើងជាសារធាតុបំពុលកំរិតមិនបានការនៅក្នុងផលិតផលនិងឧបករណ៍ប្រើប្រាស់ នឹងមិនត្រូវបានយកមកពិចារណាដើម្បីចុះក្នុងតារាងឧបសម្ព័ន្ធនេះទេ ។

( ii ) ការកត់សំគាល់នេះ នឹងមិនត្រូវបានពិចារណាចំពោះគោលបំណងដែលអាចទទួលយកបាន ឬករណីលើកលែងពិសេសនៃការផលិត និងការប្រើប្រាស់ សំរាប់គោលបំណងនៃវាក្យខ័ណ្ឌ ២ មាត្រា ៣ ។ សារធាតុគីមីមួយចំនួនដែលកើតឡើងជាធាតុផ្សំនៃឧបករណ៍ប្រើប្រាស់ដែលបានផលិត ឬប្រើប្រាស់ពីមុនមក ឬចាប់ពីថ្ងៃចូលជាធរមាននៃកាតព្វកិច្ចដែលទាក់ទងទៅនឹងសារធាតុគីមីនោះ នឹងមិនត្រូវបានយកមកពិចារណាជាការចុះបញ្ជីក្នុងតារាងឧបសម្ព័ន្ធនេះទេ ហើយដែលបានកំណត់ថា ភាគីបានជូនដំណឹងទៅលេខាធិការដ្ឋានថា

ប្រភេទនៃវត្ថុនោះ គឺកំពុងបន្តប្រើប្រាស់ដោយភាគីជាសមាជិកនោះ ។ លេខាធិការដ្ឋានត្រូវធ្វើសេចក្តីជូនដំណឹងជាសាធារណៈតាមដែលអាច ។

(iii) ការកត់សំគាល់នេះ នឹងមិនត្រូវបានពិចារណាចំពោះករណីលើកលែងពិសេសនៃការផលិត និងការប្រើប្រាស់សំរាប់គោលបំណងនៃវាក្យខ័ណ្ឌ ១ មាត្រា ៣ ។ ដោយការចាត់ថា វាមិនមានជាសារធាតុគីមីសំខាន់ៗដែលត្រូវបានគេរំពឹងថាចូលក្នុងខ្លួនមនុស្ស និងបរិស្ថាន ក្នុងពេលផលិតនិងប្រើប្រាស់ជាសារធាតុគីមីអន្តរការីដែលមានការកំណត់ក្នុងការប្រើវានៅទីតាំងបិទជិត (closed-system site-limited intermadiate) ភាគីជាសមាជិក ដោយផ្អែកលើការជូនដំណឹងជាមុនទៅលេខាធិការដ្ឋាន អាចអនុញ្ញាតឱ្យផលិតនិងការប្រើប្រាស់សារធាតុគីមីមួយចំនួនដែលបានចុះក្នុងតារាងឧបសម្ពន្ធនេះ ជាសារធាតុគីមីអន្តរការីដែលមានការកំរិតក្នុងការប្រើប្រាស់នៅទីតាំងបិទជិត (closed-system site-limited intermadiate) ដោយលក្ខណៈគីមីរបស់វាត្រូវបានបំលែងក្នុងការបង្កើតទៅជាសារធាតុគីមីដទៃ ដែលគោរពតាមល័ក្ខខ័ណ្ឌវិនិច្ឆ័យក្នុងវាក្យខ័ណ្ឌ ១ ឧបសម្ពន្ធ (ឃ) ហើយដែលសារធាតុគីមីកើតថ្មីនោះមិនបានបង្ហាញលក្ខណៈគីមីជាសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ។

សេចក្តីជូនដំណឹងជាមុនទៅលេខាធិការដ្ឋាន ត្រូវបញ្ចូលនូវពត៌មានស្តីពីបរិមាណសរុបនៃការផលិតនិងការប្រើប្រាស់នូវសារធាតុគីមីនោះ ឬធ្វើការប៉ាន់ប្រមាណឱ្យបានសមស្របនូវពត៌មាននេះ និងពត៌មានដែលទាក់ទងទៅនឹងប្រភេទនៃដំណើរការ ដែលមានការកំរិតក្នុងការប្រើប្រាស់នៅទីតាំងបិទជិត ដោយរួមបញ្ចូលនូវបរិមាណសារធាតុបំពុលដែលមិនប្រែធាតុ និងការបំពុលដែលកើតដោយឯងៗពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ (របស់ ឬវត្ថុដែលកើតមាននៅក្នុងផលិតផលដំបូង) ។

លេខាធិការដ្ឋាន ត្រូវផ្ញើរសេចក្តីជូនដំណឹងជាមុននោះទៅសន្និបាតភាគី និងធ្វើជាសាធារណៈ ។ ការផលិត និងការប្រើប្រាស់បែបខាងលើនេះ នឹងមិនត្រូវចាត់ទុកថាជាការផលិតនិងប្រើប្រាស់ក្នុងករណីពិសេសទេ ។ ការផលិតនិងការប្រើប្រាស់បែបនេះ នឹងត្រូវបញ្ចប់ក្រោយរយៈពេល ១០ ឆ្នាំបន្ទាប់ លុះត្រាតែភាគីដែលពាក់ព័ន្ធដាក់សេចក្តីជូនដំណឹងថ្មីទៅលេខាធិការដ្ឋាន ក្នុងករណីនេះរយៈពេលនឹងត្រូវបានពន្យារពេលបន្ថែម ១០ ឆ្នាំទៀត លុះត្រាតែសន្និបាតភាគីធ្វើការសំរេច ក្រោយពីការពិនិត្យឡើងវិញនូវការផលិតនិងការប្រើប្រាស់នោះ។ នីតិវិធីនៃការជូនដំណឹងអាចត្រូវបានធ្វើសារជាថ្មី ។

(iv) រាល់ការលើកលែងពិសេសក្នុងតារាងឧបសម្ពន្ធនេះ អាចត្រូវបានអនុវត្តន៍ដោយភាគី ដែលបានចុះបញ្ជីដោយអនុលោមតាមមាត្រា ១៤ ។

## ឧបសម្ព័ន្ធ ខ

### ផ្នែកទី ២

**DDT [1,1,1-trichloro-2,2-bis(4-chlorophenyl)ethane]**

១- ការផលិតនិងការប្រើប្រាស់ DDT នឹងត្រូវបានលុបបំបាត់ លើកលែងតែភាគីជាសមាជិកខ្លះដែលបានផ្ដល់ដំណឹងទៅលេខាធិការដ្ឋានពីគោលបំណងរបស់ពួកគេ ដើម្បីផលិត ឬប្រើប្រាស់វាប៉ុណ្ណោះ ។ តាមរយៈនេះ បញ្ជី DDT ត្រូវគេបង្កើតឡើងនិងអាចប្រើប្រាស់បានជាសាធារណៈ ។ លេខាធិការដ្ឋានត្រូវថែរក្សាបញ្ជី DDT ។

២- ភាគីជាសមាជិកនីមួយៗ ដែលផលិតនិងប្រើប្រាស់ DDT ត្រូវកំនត់ថាជាការផលិត ឬប្រើប្រាស់សំរាប់ការត្រួតពិនិត្យភ្នាក់ងារចំលងជម្ងឺ អនុលោមទៅតាមអនុសាសន៍របស់អង្គការសុខភាពពិភពលោក (WHO) និងគោលការណ៍ណែនាំលើការប្រើប្រាស់ DDT និងនៅពេលដែលសារធាតុសំរាប់ប្រើជំនួសអាចរកបាន មានសុវត្ថិភាព និងមានប្រសិទ្ធិភាពសំរាប់ការប្រើដែលមិនចោទជាបញ្ហាដល់ភាគីសមាជិក ។

៣- ទោះបីថា ភាគីជាសមាជិកដែលមិនបានចុះក្នុងបញ្ជី DDT បានសំរេចថាត្រូវការប្រើ DDT សំរាប់ការត្រួតពិនិត្យភ្នាក់ងារចំលងជំងឺ ចាំបាច់ត្រូវជូនដំណឹងទៅលេខាធិការដ្ឋានឱ្យបានលឿនតាមដែលអាចដើម្បីបញ្ចូលឈ្មោះទៅក្នុងបញ្ជី DDT ហើយនៅក្នុងពេលជាមួយគ្នានេះ ក៏ត្រូវជូនដំណឹងទៅអង្គការសុខភាពពិភពលោកផងដែរ ។

៤- រៀងរាល់បីឆ្នាំ ភាគីជាសមាជិកនីមួយៗដែលប្រើប្រាស់ DDT ត្រូវផ្ដល់ទៅលេខាធិការដ្ឋាននិងអង្គការសុខភាពពិភពលោក នូវពត៌មាននៃបរិមាណដែលបានប្រើប្រាស់ ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់នោះ និងយុទ្ធសាស្ត្រក្នុងការត្រួតពិនិត្យជំងឺរបស់ពួកគេ ក្នុងទំរង់ដែលបានសំរេចដោយសន្និបាតភាគី ដោយមានការពិគ្រោះយោបល់ជាមួយអង្គការសុខភាពពិភពលោក ។

៥- ជាមួយនឹងគោលបំណងធ្វើការកាត់បន្ថយ និងការបំបាត់ចោលទាំងស្រុងនូវការប្រើប្រាស់ DDT សន្និបាតភាគីត្រូវខិតខំ :

ក- រាល់ភាគីជាសមាជិកប្រើប្រាស់ DDT ត្រូវរៀបចំនិងអនុវត្តនូវផែនការសកម្មភាពដែលជាផ្នែកនៃផែនការអនុវត្តអនុសញ្ញានេះ ដូចដែលមានកំណត់នៅក្នុងមាត្រា ៧ ។ ផែនការសកម្មភាពរួមមាន :

(i) ការរៀបចំនូវបទបញ្ញា និងយន្តការផ្សេងៗដើម្បីធានាថា ការប្រើប្រាស់ DDT ត្រូវបានដាក់កំរិតសំរាប់តែការត្រួតពិនិត្យភ្នាក់ងារចំលងជំងឺ ។

(ii) ការអនុវត្តន៍នូវវិធីសាស្ត្រ យុទ្ធសាស្ត្រ និងផលិតផលជំរើសដ៏សមស្រប ដែលរួមបញ្ចូលយុទ្ធសាស្ត្រគ្រប់គ្រងយូរអង្វែង ដើម្បីធានាការបន្តនូវប្រសិទ្ធិភាពនៃការប្រើជំរើសជំនួសទាំងនោះ ។

(iii) វិធានការដើម្បីពង្រឹងការថែរក្សាសុខភាព និងដើម្បីកាត់បន្ថយគ្រោះថ្នាក់ដោយសារជំងឺ ។

ខ- នៅក្នុងក្របខ័ណ្ឌសមត្ថភាពរបស់ខ្លួន ភាគីជាសមាជិកត្រូវតែបង្កើននូវការស្រាវជ្រាវ និងរៀបចំនូវយុទ្ធសាស្ត្រ វិធីសាស្ត្រ និងផលិតផលជំរើសប្រកបដោយសុវត្ថិភាព ដែលជាសារធាតុគីមីនិងមិនមែនជាសារធាតុ សំរាប់ភាគីដែលធ្វើការប្រើប្រាស់ DDT ដែលមានការជាប់ទាក់ទងល័ក្ខខ័ណ្ឌរបស់ប្រទេសទាំងនោះ និងក្នុងទិសដៅបន្ថយនូវជំងឺ និងបន្ថយការប៉ះពាល់ផ្នែកសេដ្ឋកិច្ច ។ កត្តាមួយចំនួនដែលត្រូវបានបង្កើនឡើង នៅពេលធ្វើការពិចារណាទៅលើជំរើស ឬការប្រមូលផ្តុំនូវជំរើស គឺត្រូវរួមបញ្ចូលនូវភាពគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងអ្វីដែលកើតឡើងក្នុងបរិស្ថានពីការជំរើសនោះ ។ ការជំរើសដែលអាចសំរេចបានចំពោះ DDT គឺត្រូវមានគ្រោះថ្នាក់តិចដល់សុខភាពនិងបរិស្ថានដែលវាសមស្របសំរាប់ត្រួតពិនិត្យជំងឺ ដោយផ្អែកទៅលើល័ក្ខខ័ណ្ឌដែលមិនចោទជាបញ្ហាដល់ភាគីជាសមាជិក និងត្រូវបានគាំទ្រដោយការត្រួតពិនិត្យទិន្នន័យ ។

៦- នៅកិច្ចប្រជុំលើកទី ១ និងយ៉ាងហោចណាស់រៀងរាល់ ៣ ឆ្នាំក្រោយ ដោយមានការពិភាក្សាជាមួយនឹងអង្គការសុខភាពពិភពលោក សន្និបាតភាគីត្រូវធ្វើការវាយតម្លៃពីតំរូវការប្រើប្រាស់ DDT ជាបន្តសំរាប់ការត្រួតពិនិត្យភ្នាក់ងារចំលងជំងឺ ដោយផ្អែកទៅលើមូលដ្ឋានពត៌មានវិទ្យាសាស្ត្រ បច្ចេកទេសបរិស្ថាន និងសេដ្ឋកិច្ចដែលអាចរកបាន ដែលរួមបញ្ចូល :

ក- ការផលិត និងការប្រើប្រាស់ DDT និងល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌ ២

ខ- ភាពដែលអាចរកបាន ភាពសមស្រប និងការអនុវត្តនូវជំរើសចំពោះ DDT

គ- ការរីកចំរើនក្នុងការបង្កើនសមត្ថភាពរបស់ប្រទេសនានា ដើម្បីផ្តល់នូវសុវត្ថិភាពដោយពឹងផ្អែកទៅលើមធ្យោបាយផ្សេងៗ ។

៧. នៅពេលណាក៏ដោយ ភាគីជាសមាជិកអាចដកឈ្មោះចេញពីបញ្ជី DDT ដោយយោងទៅលើលិខិតជូនដំណឹងជាលាយល័ក្ខអក្សរជាមុនទៅលេខាធិការដ្ឋាន ។ ការដកឈ្មោះចេញពីបញ្ជី DDT នឹងត្រូវចាត់ទុកជាផ្លូវការនៅថ្ងៃដែលបានកំណត់ក្នុងលិខិតជូនដំណឹងជាមុន ។

សេចក្តីបកប្រែមិនផ្លូវការ

# ឧបសម្ព័ន្ធ គ

# ការកកើតផលិតផលដែលមិនចង់បាន

## ផ្នែកទី ១

## សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុដែលស្ថិតនៅក្រោមល័ក្ខខ័ណ្ឌនៃមាត្រា ៥

ឧបសម្ព័ន្ធនេះអនុវត្តទីចំពោះសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដូចខាងក្រោម នៅពេលដែលកកើត និងសាយភាយដោយអចេតនាចេញពីសកម្មភាពមនុស្ស :

| សារធាតុគីមី |
|---|
| Polyclorinated dibenzo-p-dioxins (PCDD) ឌីអុកស៊ីន |
| Polyclorinated dibenzofurans (PCDF) ហ្វូរ៉ាន់ |
| Hexachlorobenzene (HCB) (CAS No:118-74-1) |
| Polychlorinated biphenyls (PCB) |

## ផ្នែកទី ២

## ប្រភេទនៃប្រភព

Plolychlorinated dibenzo-p-dioxins និង dibenzofurans, hexachlorobenzeng និង polychlorinated biphenyls គឺជាសារធាតុគីមីដែលកើតឡើង និងសាយភាយដោយអចេតនាចេញពីប្រភពដែលមានដំណើរចំហេះរវាងសារធាតុសរីរាង្គនិងក្លរ ដែលជាលទ្ធផលនៃចំហេះមិនសព្វ ឬប្រតិកម្មគីមី ។ ប្រភេទប្រភពឧស្សាហកម្មខាងក្រោម គឺមានសក្តានុពលខ្ពស់ក្នុងការផលិត និងសាយភាយយ៉ាងច្រើននូវសារធាតុគីមីទាំងនោះទៅក្នុងបរិស្ថាន ។

ក- ឡដុតសំណល់ រាប់បញ្ចូលឡដុតសំណល់រួមនៃសំណល់ទីក្រុង សំណល់គ្រោះថ្នាក់ ឬសំណល់មន្ទីរពេទ្យ ឬសំណល់ភក់ទឹកល្អ ។

ខ- ឡស៊ីម៉ង់ដែលដុតសំណល់គ្រោះថ្នាក់ជាថាមពល ។

គ- ការផលិតម្សៅក្រដាសដោយប្រើក្លរ ឬសារធាតុគីមីដែលបង្កើតដោយធាតុក្លរសំរាប់ធ្វើឱ្យមានពណ៌ស ។

ឃ- ខាងក្រោមនេះ គឺជាដំណើរចំហេះនៅក្នុងឧស្សាហកម្មលោហៈ

(i) ការផលិតស្ពាន់ដំណាក់ទី ២

(ii) ការស៊ំយោគនៅក្នុងឧស្សាហកម្មដែកថែបនិងដែក

(iii) ការផលិតអាលុយមីញ៉ូមដំណាក់ទី ២

(iv) ការផលិតស័ង្កសីដំណាក់ទី ២ ។

សេចក្តីបកប្រែមិនផ្លូវការ

## ផ្នែកទី ៣

## ប្រភេទនៃប្រភព

Ployclorinated dibenzo-p-dioxins និង dibenzofurans, hexachlorobenzene និង polychlorinated biphenyl អាចត្រូវបានបង្កើតឡើង ឬសាយភាយដោយអចេតនា ពីប្រភពផ្សេងៗ រួមបញ្ចូលទាំង :

ក- ការដុតសំណល់នៅទីវាល រាប់បញ្ចូលទាំងការដុតសំណល់នៅទីលានចាក់សំរាម

ខ- ដំណើរចំហេះនៅក្នុងឧស្សាហកម្មលោហៈ ដែលមិនបានចែងនៅក្នុងផ្នែកទី ២

គ- ប្រភពចំហេះតាមលំនៅស្ថាន

ឃ- រោងចក្រអគ្គិសនីដុតប្រេងផូស៊ីល និងរោងចក្រផលិតចំហាយ

ង- ការដុតឈើ និងការដុតសំណល់លាមកសត្វ ស្លឹកឈើ ( Biomass )

ច- ដំណើរការផលិតសារធាតុគីមីដែលសាយភាយសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដែលកកើតដោយអចេតនា ជាពិសេសការផលិត Chlorophenols និង Chloranil

ឆ- ម៉ាឆាដុតសព

ជ- ទោចក្រយានយន្ត ជាពិសេសប្រភេទដែលប្រើប្រាស់ប្រេងសាំងមានជាតិសំណ

ឈ- ការបំផ្លាញនូវសាកសពសត្វ

ញ- រោងចក្រតំបាញ រោងចក្រជ្រលក់ពណ៌ស្បែកសត្វ ( ប្រើប្រាស់សារធាតុ Chloranil ) និងរោងចក្រក្រូម៉េ

ដ- រោងចក្រកំទេចរថយន្តចាស់ៗដែលលែងប្រើ

ឋ- ការដុតខ្សែភ្លើងយកស្ពាន់

ឌ- ការចំរាញ់សំណល់ប្រេង ។

## ផ្នែកទី ៤

## និយមន័យ

ក- សំរាប់គោលបំណងនៃឧបសម្ពន្ធនេះ :

ក- " Polychlorinated biphenyls " គឺជាសមាសធាតុអ៊ីដ្រូកាបូប្រហើរ ដែលកើតក្នុងទំរង់ដែលអាតូមអ៊ីដ្រូសែនភ្ជាប់ជាមួយនឹងម៉ូលេគុល biphenyl ( វ៉ាឌីកាល់បង់សែនទាំងពីរបានភ្ជាប់គ្នាដោយឆ្អឹងកាបូន-កាបូនទោល ) ដែលអាចត្រូវជំនួសដោយអាតូមក្លរហូតដល់ ១០ ។

ខ- "Polychlorinated dibenzo-p-dioxins" និង "polychlorinated dibenzofurans" គឺជាបង្គុំខ្សែបិទបីនៃសមាសធាតុអ៊ីដ្រូកាបូប្រហើរ ដែលបង្កើតដោយវ៉ាឌីកាល់បង់សែនពីរភ្ជាប់ដោយអាតូមអុកស៊ីសែន ២ ក្នុង polychlorinated dibenzo-p-dioxins និងដោយអាតូមអុកស៊ីសែន ១ ទៅនឹងឆ្អឹងកាបូន-កាបូនមួយក្នុង polychlorinated dibenzofurans និងអាតូមអ៊ីដ្រូសែនមួយចំនួនដែលអាចជំនួសដោយអាតូមក្លរចំនួនដល់ទៅ ៨ ។

ខ- នៅក្នុងឧបសម្ព័ន្ធនេះ កំរិតភាពពុលរបស់ឌីអុកស៊ីន និងហ្វ៊ូរ៉ាន់ (Polychlorinated dibenzo-p-dioxins និង dibenzofurans) គឺត្រូវបានសម្តែងដោយខ្នាតនៃភាពពុលជាអេគីវ៉ាឡង់ (TEQ) ដែលជាខ្នាតនៃភាពពុលរួមរបស់ក្រុមអំបូរនៃឌីអុកស៊ីន និងហ្វ៊ូរ៉ាន់ និងពពួក coplanar polychlorinated biphenyls ក្នុងការធៀបទៅនឹង ២,៣,៧,៨-Tetrachlorodibenzo-p-dioxin ។ តំលៃឯកតាអេគីវ៉ាឡង់របស់ជាតិពុល ដែលប្រើសំរាប់គោលបំណងនៃអនុសញ្ញានេះ នឹងត្រូវស្របជាមួយស្តង់ដារអន្តរជាតិដែលបានទទួលការអនុម័ត ដោយការចាប់ផ្តើមរបស់អង្គការសុខភាពពិភពលោកក្នុងឆ្នាំ ១៩៩៨ ជាតំលៃកត្តាអេគីវ៉ាឡង់នៃភាពពុលសំរាប់ឌីអុកស៊ីន និងហ្វ៊ូរ៉ាន់ និងពពួក coplanar polychlorinated biphenyls ។ កំហាប់របស់សារធាតុទាំងនោះ គឺត្រូវបានសំដែងជាភាពពុលអេគីវ៉ាឡង់ (Toxicity Equivalence) ។

## ផ្នែកទី ៥

## ការណែនាំទូទៅលើបច្ចេកវិទ្យាដ៏ប្រសើរដែលអាចរកបាន និងការអនុវត្តន៍បរិស្ថានដ៏ប្រសើរ

ផ្នែកនេះបានផ្តល់នូវការណែនាំទូទៅដល់ភាគីជាសមាជិក លើការការពារ និងកាត់បន្ថយការសាយភាយនូវសារធាតុគីមី ដែលមានចែងក្នុងផ្នែកទី ១ ។

### ក. វិធានការការពារទូទៅទាក់ទងនឹងបច្ចេកវិទ្យាដ៏ប្រសើរដែលអាចរកបាន និងការអនុវត្តន៍បរិស្ថានដ៏ប្រសើរ

កត្តាជាអាទិភាព នឹងត្រូវបានគេផ្តល់ចំពោះការពិចារណាលើដំណោះស្រាយ ដើម្បីទប់ស្កាត់ការបង្កើត និងការសាយភាយសារធាតុគីមីដែលមានចែងក្នុងផ្នែកទី ១ ។ វិធានការដែលមានប្រយោជន៍អាចរួមមាន :

ក- ការប្រើប្រាស់បច្ចេកវិទ្យាដែលមានសំណល់តិច

ខ- ការប្រើប្រាស់សារធាតុដែលមានកំរិតគ្រោះថ្នាក់ទាប

គ- ការធ្វើឱ្យកាន់តែប្រសើរនូវការប្រើប្រាស់ និងការកែច្នៃនូវសំណល់ និងសារធាតុដែលត្រូវបាន បង្កើត និងប្រើប្រាស់ក្នុងដំណើរការផលិតកម្ម ។

ឃ- ការជំនួសនូវសមាសធាតុផ្គត់ផ្គង់ ដែលជាសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ឬនៅកន្លែងដែលមានការជាប់ទាក់ទងរវាងវត្ថុធាតុដើម និងការសាយភាយសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុពីប្រភព ។

ង- កិច្ចគ្រប់គ្រងល្អ និងកម្មវិធីតំហែទាំ ។

ច- ការធ្វើឱ្យប្រសើរក្នុងការគ្រប់គ្រងសំណល់ ក្នុងគោលបំណងនៃការបញ្ឈប់ចំពោះការដុតសំណល់នៅកណ្តាលវាល ដោយគ្មានការត្រួតពិនិត្យរាប់បញ្ចូលទាំងការដុតនៅទីលានចាក់សំណល់ ។ នៅពេលពិនិត្យលើសំណើដើម្បីសាងសង់បរិក្ខារចោលសំណល់ថ្មី គួរពិចារណាជំរើសមួយចំនួនដូចជាសកម្មភាពដើម្បីបន្ថយការបង្កើតសំណល់ពីទីក្រុង និងសំណល់មន្ទីរពេទ្យ ដោយរួមបញ្ចូលនូវការសន្សំសំចៃនូវធនធាន ការប្រើប្រាស់ឡើងវិញ ការកែច្នៃ ការញែកសំណល់តាមប្រភេទ និងការធ្វើឱ្យប្រសើរនូវការផលិតដែលបង្កើតសំណល់តិច ។ នៅក្នុងដំណោះស្រាយនេះ បញ្ហាសុខភាពសាធារណៈគួរត្រូវគិតគូរដោយប្រុងប្រយ័ត្ន ។

ឆ- ការធ្វើឱ្យថយចុះនូវសារធាតុគីមីទាំងនោះ ក៏ដូចជាភាពពុលក្នុងផលិតផល ។

ជ- ការជៀសវាងការប្រើប្រាស់ធាតុក្លរ ឬសារធាតុគីមីដែលមានជាតិក្លរសំរាប់ការធ្វើឱ្យមានពណ៌ស ។

## ខ. បច្ចេកទេសដ៏ប្រសើរដែលអាចរកបាន

នៅក្នុងទស្សនៈនៃបច្ចេកទេសដ៏ប្រសើរដែលអាចរកបាន គឺមិនសំដៅទៅលើការប្រកាន់យកនូវបច្ចេកទេស ឬបច្ចេកវិជ្ជាជាក់លាក់ណាមួយនោះទេ ប៉ុន្តែ គឺជាការគិតគូរផងដែរនូវលក្ខណៈបច្ចេកទេសនៃការដំឡើង ឬសាងសង់ដែលមានការពាក់ព័ន្ធ ដូចជា ទីតាំងភូមិសាស្ត្ររបស់គំរោង និងល័ក្ខខ័ណ្ឌបរិស្ថានក្នុងតំបន់នោះ ។ បច្ចេកទេសត្រួតពិនិត្យដ៏សមស្រប ដើម្បីកាត់បន្ថយការសាយភាយសារធាតុគីមីដែលមាននៅក្នុងផ្នែកទី ១ គឺជាទូទៅវាមានលក្ខណៈដូចគ្នា ។ នៅក្នុងការកំណត់នូវបច្ចេកទេសដ៏ប្រសើរដែលអាចរកបាន ការពិចារណាពិសេសគួរត្រូវបានផ្តល់ជាករណីទូទៅ ឬពិសេសចំពោះកត្តាខាងក្រោមដូចជា ការទាក់ទងរវាងតំលៃនិងសារៈប្រយោជន៍នៃវិធានការ និងការពិចារណាលើការបង្ការ និងការការពារ :

ក- ការគិតពិចារណាទូទៅ :

(i) ប្រភេទ ឥទ្ធិពល និងបរិមាណនៃការសាយភាយដែលមានការពាក់ព័ន្ធ ដូចជាបច្ចេកទេសអាចប្រែប្រួលអាស្រ័យទៅលើទំហំនៃប្រភព ។

(ii) ការកំណត់ពេលវេលាសំរាប់ការសាងសង់ថ្មី ឬដែលមានស្រាប់ ។

(iii) ពេលវេលាដែលត្រូវការចាំបាច់ដើម្បីណែនាំបង្ហាញបច្ចេកទេសដ៏ប្រសើរដែលអាចរកបាន ។

(iv) តំរូវការប្រើប្រាស់និងប្រភេទនៃវត្ថុធាតុដើម ដែលប្រើប្រាស់ក្នុងដំណើរការផលិត និងប្រសិទ្ធិភាពថាមពលរបស់វា ។

(v) តម្រូវការដើម្បីការពារ ឬកាត់បន្ថយផលប៉ះពាល់ទូទៅឱ្យដល់កំរិតទាបបំផុតចំពោះការសាយភាយទៅក្នុងបរិស្ថាន និងគ្រោះថ្នាក់ចំពោះបរិស្ថាន ។

(vi) តម្រូវការដើម្បីទប់ស្កាត់នូវគ្រោះថ្នាក់ និងដើម្បីធ្វើឱ្យថយចុះផលវិបាកគ្រោះថ្នាក់ចំពោះបរិស្ថាន ។

(vii) តម្រូវការដើម្បីធានានូវសុខភាពអ្នកបំពេញការងារ និងសុវត្ថិភាពនៅកន្លែងធ្វើការ ។

(viii) ដោយប្រៀបធៀបនូវដំណើរការផលិត សំភារៈបរិក្ខារ ឬវិធីសាស្ត្រនៃដំណើរការផលិតដែលបានទទួលជោគជ័យលើផ្នែកឧស្សាហកម្ម ។

(ix) ភាពជឿនលឿននៃបច្ចេកវិទ្យា និងការផ្លាស់ប្តូរចំណេះដឹងវិទ្យាសាស្ត្រ និងការយល់ដឹង ។

ខ- វិធានការកាត់បន្ថយនូវការបញ្ចេញចោលទូទៅ : នៅពេលពិនិត្យសំណើដើម្បីសាងសង់សំណង់ថ្មី ឬធ្វើការកែប្រែក្នុងទំរង់ទ្រង់ទ្រាយធំនូវអគារ ឬគ្រឿងបរិក្ខារដែលមានស្រាប់ដែលដំណើរការផលិតកម្មរបស់វាបញ្ចេញនូវសារធាតុគីមីដែលមានចែងនៅក្នុងឧបសម្ព័ន្ធនេះ ការគិតគូរពិចារណាជាអាទិភាពគួរតែត្រូវផ្តល់លើជំរើសដំណើរការផលិតកម្ម បច្ចេកទេស ការអនុវត្តដែលមានសារៈប្រយោជន៍ដូចគ្នា ប៉ុន្តែ ជៀសវាងការបង្កើត និងការបញ្ចេញនូវសារធាតុគីមីទាំងនោះ ។ នៅក្នុងករណីដែលអាគារ ឬគ្រឿងបរិក្ខារទាំងនោះត្រូវបានសាងសង់ ឬត្រូវបានកែប្រែ ការបន្ថែមនូវវិធានការការពារដែលបានបញ្ជាក់នៅក្នុងចំនុច ក នៃផ្នែកទី ៥ វិធានការកាត់បន្ថយខាងក្រោមនេះអាចត្រូវបានគេគិតពិចារណាផងដែរ ក្នុងការកំណត់នូវបច្ចេកទេសដ៏ប្រសើរដែលអាចប្រព្រឹត្តទៅបាន :

(i) ប្រើប្រាស់នូវវិធីសាស្ត្រទំនើបសំរាប់សំអាតបំពង់ផ្សែង ដូចជា ការកំដៅ ឬអុកស៊ីតកម្មដោយកាតាលីករ ការប្រើតំណក់ទឹកសំរាប់ស្ទាក់ម្រែងផ្សែង ឬធូលី ។

(ii) ការសំអាតរបស់សល់ សំណល់រាវ សំណល់កកល្អតាមរយៈប្រព្រឹត្តកម្មសំអាតដោយកំដៅ ឬការចំរាញ់ជាតិពុល ឬប្រតិកម្មគីមីដើម្បីបំបាត់ជាតិពុល ។

(iii) ការផ្លាស់ប្តូរដំណើរការ ដែលនាំទៅដល់ការកាត់បន្ថយ ឬការបំបាត់នូវការបញ្ចេញចោលដូចជាការផ្លាស់ប្តូរប្រព័ន្ធដែលចាស់ ។

(iv) ការផ្លាស់ប្តូរនូវគំរោងដំណើរផលិតកម្ម ដើម្បីធ្វើឱ្យប្រសើរនូវចំហេះ និងការការពារការកើតឡើងនូវសារធាតុគីមី ដែលមាននៅក្នុងបញ្ជីនៃឧបសម្ព័ន្ធនេះ តាមរយៈនៃការត្រួតពិនិត្យនូវប៉ារ៉ាម៉ែត្រមួយចំនួន ដូចជា សីតុណ្ហភាពឡដុតសំរាម ឬរយៈពេលស្ថិតនៅ ។

## គ. **ការអនុវត្តបរិស្ថានដ៏ប្រសើរ**

សន្និបាតភាគីនឹងរៀបចំគោលការណែនាំដែលទាក់ទងការអនុវត្តបរិស្ថានដ៏ប្រសើរ ។

សេចក្តីបកប្រែមិនផ្លូវការ

# ឧបសម្ព័ន្ធ ឃ

# តំរូវការព័ត៌មាន និងល័ក្ខខ័ណ្ឌវិនិច្ឆ័យ

១- ភាគីជាមាជិកដែលបានដាក់សំណើដើម្បីចុះបញ្ជីសារធាតុគីមីនៅក្នុងឧបសម្ព័ន្ធ ( ក ) ឧបសម្ព័ន្ធ ( ខ ) ឬ ឧបសម្ព័ន្ធ ( គ ) ត្រូវបង្ហាញពីសារធាតុគីមីនោះក្នុងរបៀបដែលបានពិពណ៌នាក្នុងកថាខ័ណ្ឌ ក ខាងក្រោម និងផ្តល់នូវពត៌មានពីសារធាតុគីមីនោះ និងផលិតផលរបស់វាដែលត្រូវបំលែងដែលទាក់ទងទៅនឹងល័ក្ខខ័ណ្ឌវិនិច្ឆ័យដែល មានចែងនៅក្នុងកថាខ័ណ្ឌពី ខ ដល់ ង ៖

ក- ការបង្ហាញសារធាតុគីមី

( i ) ឈ្មោះ រួមទាំងឈ្មោះសំរាប់ធ្វើជំនួញមួយឬច្រើន ឬឈ្មោះដ៏ទៃទៀត ឈ្មោះសំរាប់ធ្វើពាណិជ្ជកម្មមួយឬច្រើន និងឈ្មោះដែលមានន័យស្មើគ្នា ចំនួនចុះបញ្ជី Chemical Abstract Service (CAS ) ឈ្មោះ International Union of Pure and Apllied Chemistry (IUPAC )

( ii ) ទំរង់សម្ព័ន្ធគីមីរួមទាំងការបញ្ជាក់ច្បាស់ពីអ៊ីសូមែដែលអាចមាន និងទំរង់សម្ព័ន្ធថ្នាក់គីមី ។

ខ- ភាពមិនងាយបំបែកធាតុ (persistance)

( i ) បង្ហាញថា ពាក់កណ្តាលជីវិតនៃសារធាតុគីមីនៅក្នុងទឹក គឺមានរយៈពេលច្រើនជាង ២ ខែ ឬពាក់កណ្តាលជីវិតរបស់វានៅក្នុងដី គឺច្រើនជាង ៦ ខែ ឬពាក់កណ្តាលជីវិតរបស់វានៅក្នុងកករដី គឺច្រើនជាង ៦ ខែ ។ ឬ

( ii ) បង្ហាញថា សារធាតុគីមីគឺវាមានភាពធន់គ្រប់គ្រាន់ ដើម្បីធ្វើការតំរូវចំពោះការពិចារណារបស់វានៅក្នុងទំហំវិសាលភាពនៃអនុសញ្ញានេះ ។

គ- ការកើនឡើងនូវបរិមាណក្នុងភាវៈរស់ (bioaccumulation)

( i ) បង្ហាញថា កត្តាប្រមូលផ្តុំក្នុងភាវៈរស់ ឬកត្តាកំណើនបរិមាណក្នុងភាវៈរស់ក្នុងពពួកសត្វក្នុងទឹក គឺច្រើនជាង ៥០០០ ឬក្នុងការអវត្តមានទិន្នន័យបែបនេះ បង្ហាញថា Log Kow គឺត្រូវធំជាង ៥ ។

( ii ) បង្ហាញថា វត្តមាននៃសារធាតុគីមីជាហេតុផលនៃការព្រួយបារម្ភ ដូចជាភាពកំណើនបរិមាណក្នុងពពួកសត្វដ៏ទៃទៀត ភាពពុល ឬភាពពុលអេកូឡូស៊ីមានកំរិតខ្ពស់ ។ ឬ

(iii) ត្រួតពិនិត្យទិន្នន័យនៅក្នុងសត្វទឹក (Biota) ដែលបានបង្ហាញថាសក្តានុពលនៃភាពកំណើនបរិមាណសារធាតុគីមីទាំងនោះក្នុងភាវៈរស់ គឺវាសមល្មមធ្វើការពិនិត្យពិច័យក្នុងវិសាលភាពនៃអនុសញ្ញានេះ ។

ឃ- <u>សក្តានុពលបំលាស់ទីរយៈចំងាយឆ្ងាយក្នុងបរិស្ថាន</u>

(i) កំរិតនៃសារធាតុគីមីក្នុងតំបន់ឆ្ងាយពីប្រភពនៃការសាយភាយរបស់វា ដែលបានវាស់ឃើញ គឺជាការព្រួយបារម្ភយ៉ាងខ្លាំង ។

(ii) ការត្រួតពិនិត្យទិន្នន័យដែលបានបង្ហាញថា ការចំលងសារធាតុគីមីក្នុងបរិស្ថានរយៈចំងាយឆ្ងាយ ដោយមានសក្តានុពលចំលងទៅក្នុងកន្លែងទទួលបរិស្ថាន ដែលអាចកើតមានតាមរយៈខ្យល់ ទឹក ឬតាមពពួកសត្វដែលបំលាស់ទី ។ ឬ

(iii) លក្ខណៈវិវត្តន៍ក្នុងបរិស្ថាន និង/ឬ លទ្ធផលគំរូដែលបានបង្ហាញថា សារធាតុគីមីនោះ មានសក្តានុពលសំរាប់បំលាស់ទីក្នុងបរិស្ថានរយៈចំងាយឆ្ងាយតាមរយៈខ្យល់ ទឹក ឬតាមពពួកសត្វដែលបំលាស់ទី ដោយសក្តានុពលសំរាប់ចំលងទៅក្នុងកន្លែងទទួលបរិស្ថាន ដែលជាទីតាំងស្ថិតនៅឆ្ងាយពីប្រភពដែលវាសាយភាយ ។ សំរាប់សារធាតុគីមីដែលភាគច្រើនបំលាស់ទីតាមខ្យល់ នោះពាក់កណ្តាលជីវិតវាក្នុងខ្យល់នឹងមានរយៈពេលច្រើនជាង ២ ថ្ងៃ ។

ង- <u>ឥទ្ធិពលអាក្រក់</u>

(i) ភស្តុតាងពីឥទ្ធិពលអាក្រក់លើសុខភាពមនុស្ស ឬចំពោះបរិស្ថាន ដែលត្រូវធ្វើឱ្យមានការពិចារណានៃសារធាតុគីមីក្នុងវិសាលភាពនៃអនុសញ្ញានេះ ។

(ii) ទិន្នន័យភាពពុល ឬភាពពុលអេកូឡូស៊ី បានបង្ហាញនូវសក្តានុពលគ្រោះថ្នាក់ចំពោះសុខភាពមនុស្ស ឬចំពោះបរិស្ថាន ។

២- ភាគីជាសមាជិកដែលធ្វើសំណើឡើង ត្រូវតែផ្តល់របាយការណ៍ពីហេតុផលនៃការព្រួយបារម្ភតាមដែលអាចរួមមាន : ការប្រៀបធៀបទិន្នន័យភាពពុល ឬទិន្នន័យភាពពុលអេកូឡូស៊ីដែលរកឃើញ ឬដែលរំពឹងគិតពីកំរិតនៃសារធាតុគីមី ដែលជាលទ្ធផលនៃការបំលាស់ទីក្នុងបរិស្ថានរយៈចំងាយឆ្ងាយពេលវែង និងរបាយការណ៍សង្ខេបដែលបង្ហាញពីតំរូវការសំរាប់ត្រួតពិនិត្យជារួម ។

៣- ភាគីជាសមាជិកដែលធ្វើសំណើឡើងទាក់ទងនឹងការពង្រីកសមត្ថភាពរបស់ខ្លួន ត្រូវផ្តល់ពត៌មានបន្ថែមដើម្បីជួយដល់ការពិនិត្យឡើងវិញនូវអ្វីដែលបានរៀបរាប់ក្នុងវាក្យខ័ណ្ឌ ៦ នៃមាត្រា ៨ ។ ក្នុងការរៀបចំគំរោងស្នើសុំបែបនេះ ភាគីសមាជិកអាចធ្វើការសុំការជួយពីផ្នែកបច្ចេកទេសពីប្រភពណាមួយ ។

សេចក្តីបកប្រែមិនផ្លូវការ

## ឧបសម្ព័ន្ធ ខ

## គំរូចការព័ត៌មានសំរាប់របាយការណ៍ភាពគ្រោះថ្នាក់

គោលបំណងនៃការពិនិត្យឡើងវិញ គឺដើម្បីវាយតំលៃថាតើធាតុគីមីទំនងជានាំឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬប៉ះពាល់ដល់បរិស្ថាន ដោយសារលទ្ធផលនៃការបំលាស់ទីក្នុងបរិស្ថានរយៈចំងាយឆ្ងាយ ដែលវិធានការរួមបែបនេះត្រូវបានបង្ហាញ ។ សំរាប់គោលបំណងនេះ របាយការណ៍ភាពគ្រោះថ្នាក់នឹងត្រូវបានរៀបចំដោយបរិយាយឱ្យបានលំអិតថែមទៀត ទៅលើពត៌មានដូចមានចែងក្នុងឧបសម្ព័ន្ធ (ឃ) និងរួមបញ្ចូលនូវប្រភពពត៌មាន ដូចខាងក្រោម :

ក- ប្រភពដែលត្រូវបញ្ចូល :

(i) ទិន្នន័យការផលិត រួមបញ្ចូលទាំងបរិមាណ និងទីតាំង

(ii) ការប្រើប្រាស់

(iii) ការសាយភាយ ដូចជា : ការបញ្ចេញចោល ការបាត់បង់ និងការភាយចេញ ។

ខ- ការវាយតំលៃគ្រោះថ្នាក់សំរាប់ចំនុចចុងក្រោយ ឬចំនុចចុងក្រោយនៃបញ្ហា ដោយរួមបញ្ចូលទាំងការវិនិច្ឆ័យលើសកម្មភាពទៅវិញទៅមកនៃតុកស៊ីកូឡូស៊ី ដែលទាក់ទងជាមួយសារធាតុគីមីជាច្រើន ។

គ- ការវិវត្តន៍នៃបរិស្ថាន ដែលរួមបញ្ចូលទាំងទិន្នន័យនិងពត៌មាន ស្តីពី សារធាតុគីមី និងលក្ខណៈរូបនៃសារធាតុគីមី ព្រមទាំងភាពធន់របស់វា និងការទាក់ទងទៅនឹងការបំលាស់ទីរបស់វាក្នុងបរិស្ថាន ការចំលងនៅក្នុង និងរវាងផ្នែកបរិស្ថានដទៃទៀត ការបំបែក និងការបំលែងទៅជាសារធាតុគីមីដទៃទៀត ។ ការកំណត់នូវកត្តាប្រមូលផ្តុំជីវៈ ឬកត្តាកំណើនជីវៈ (bio-concentration factor or bio-accumulation factor) ដែលផ្អែកទៅលើតំលៃដែលបានកំណត់នឹងត្រូវធ្វើឡើង លើកលែងតែនៅពេលធ្វើការត្រួតពិនិត្យទិន្នន័យ ត្រូវបានតំរូវដើម្បីឆ្លើយតបទៅនឹងតំរូវការនេះ ។

ឃ- ធ្វើការត្រួតពិនិត្យទិន្នន័យ ។

ង- ការទទួលរងនៅទីកន្លែងខាងក្នុង ពិសេស ដោយសារលទ្ធផលនៃការបំលាស់ទីក្នុងបរិស្ថានរយៈពេលវែង និងរួមបញ្ចូលនូវពត៌មានដែលទាក់ទងទៅនឹងលទ្ធភាពដែលអាចកើតមានខាងជីវៈ ។

ច- ការវាយតំលៃពីភាពគ្រោះថ្នាក់ក៏រិតជាតិ និងអន្តរជាតិ ការប៉ាន់ប្រមាណ និងការបិទស្លាកសញ្ញាពត៌មាន និងការចាត់ថ្នាក់ប្រភេទគ្រោះថ្នាក់ដែលអាចកើតមាន ។

ឆ- ស្ថានភាពនៃសារធាតុគីមីនៅក្រោមអនុសញ្ញាអន្តរជាតិទាំងអស់ ។

## ឧបសម្ព័ន្ធ ច

## ព័ត៌មានដែលនាំទៅការពិចារណាលើសេដ្ឋកិច្ចសង្គម

ការវាយតំលៃនឹងត្រូវបានទទួលធ្វើចំពោះវិធានការត្រួតពិនិត្យ ដែលអាចសំរាប់សារធាតុគីមីនៅក្រោមការពិចារណាសំរាប់បញ្ចូលក្នុងអនុសញ្ញានេះ ដោយរួមបញ្ចូលការគ្រប់គ្រងនិងការលុបចំបាត់ចោល ។ សំរាប់គោលបំណងនេះ ពត៌មានពាក់ព័ន្ធនឹងត្រូវផ្តល់ចំពោះការវិនិច្ឆ័យលើសេដ្ឋកិច្ចសង្គម ដោយភ្ជាប់ជាមួយនឹងវិធានការត្រួតពិនិត្យដែលអាច ដើម្បីជំរុញការសំរេចចិត្តដែលនឹងត្រូវអនុម័តដោយសន្និបាតភាគី ។ ពត៌មានបែបនេះ ត្រូវមានភាពប្រែប្រួលទៅតាមសមត្ថភាពនិងល័ក្ខខ័ណ្ឌផ្សេងៗរបស់ភាគីជាសមាជិក ហើយត្រូវបញ្ចូលការពិចារណាទៅលើបញ្ជីបានរៀបរាប់ខាងក្រោម :

១- គុណភាព

និងប្រសិទ្ធិភាពនៃវិធានការត្រួតពិនិត្យដែលអាចប្រព្រឹត្តទៅបានក្នុងការឆ្លើយតបនូវគោលបំណងកាត់បន្ថយភាពគ្រោះថ្នាក់ :

ក- លទ្ធភាពបច្ចេកទេសដែលអាចធ្វើទៅបាន

ខ- តម្លៃ ដែលរួមបញ្ចូលតំលៃបរិស្ថាន និងសុខភាព

២- ការប្រើជំរើសជំនួស (ផលិតផល និងដំណើរការផលិត)

ក- លទ្ធភាពបច្ចេកទេសដែលអាចធ្វើទៅបាន

ខ- តម្លៃ ដែលរួមបញ្ចូលតំលៃបរិស្ថាន និងសុខភាព

គ- គុណភាព

ឃ- ភាពដែលប្រឈមមុខនឹងគ្រោះថ្នាក់

ង- ភាពដែលអាចយកមកប្រើប្រាស់បាន

ច- ភាពដែលអាចទទួលយកបាន

៣- ការប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានទៅលើសង្គម តាមរយៈការអនុវត្តន៍វិធានការត្រួតពិនិត្យដែលអាចធ្វើទៅបាន :

ក- សុខភាព ដែលរួមបញ្ចូលសុខភាពសារធារណៈ បរិស្ថាន និងសុខភាពនៃការងារ

ខ- កសិកម្ម ដែលរួមបញ្ចូលវារីវប្បកម្ម និងផ្នែកព្រៃឈើ

គ- ជីវិតសត្វទឹក (ជីវចំរុះ)

ឃ- ទិដ្ឋភាពសេដ្ឋកិច្ច

ង- ការជំរុញទៅមុខនូវការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

ច- តម្លៃសង្គម

៤- ការជាប់ទាក់ទងរវាងសំណល់ និងការបោះបង់ចោល (ជាពិសេស ស្តុកនៃថ្នាំសំលាប់សត្វល្អិតដែលខូចគុណភាព) និងការសំអាតទីតាំងដែលបានទទួលរងការបំពុល) :

ក- លទ្ធភាពបច្ចេកទេសដែលអាចធ្វើទៅបាន

ខ- តម្លៃ

៥- ភាពដែលអាចទទួលបាននូវពត៌មាន និងការអប់រំជាសាធារណ:

៦- ស្ថានភាពនៃការត្រួតពិនិត្យ សមត្ថភាពតាមដាន (monitoring)

៧- សកម្មភាពត្រួតពិនិត្យក្នុងក្របខ័ណ្ឌជាតិ ឬតំបន់ដែលត្រូវដាក់ចេញ រួមមាន ពត៌មានពីការប្រើជំរើសផ្សេងៗ និងពត៌មានទាក់ទងទៅនឹងការគ្រប់គ្រងពីភាពប្រឈមទៅនឹងគ្រោះថ្នាក់ដ៏ទៃទៀត ។